សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែល បង្កឡើងដោយសំណង់ជាប់នឹងដី

ស្រាវជ្រាវពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ ៖ **ទូច គីមហ៊ិត**

សាស្ត្រាចារ្យណែនាំ៖

**លោក គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ទូច គីមហ៊ត ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

ខ្ញុំបាទសូមធ្វើការថ្លែងអំណរគុណ និង សម្តែងនូវកត្តញ្ញូតាធម៌ ជូនចំពោះ ៖

លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់រូបកូន និង បានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ និងបានផ្តល់ក្តីស្រលាញ់ជូនចំពោះរូបកូនបានយ៉ាងល្អ តាំងពីពេលចាប់កំណើត រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត លោកអ្នកមានគុណ បានខិតខំប្រឹងប្រែង និងលះបង់ គ្រប់បែបយ៉ាងនូវកម្លាំងកាយកម្លាំងចិត្ត ជាពិសេសពេលវេលាជាច្រើនដើម្បីផ្គត់ផ្គង់ដល់ជីវភាពរស់នៅ និង ឧបត្ថម្ភគ្រប់សព្វបែបយ៉ាង ដូចជាសម្ភារៈសិក្សាបានគ្រប់គ្រាន់ ដើម្បីឲ្យកូនបានសិក្សា និង ទទួលបានចំណេះវិជ្ជា ដោយមិនគិតពីភាពនឿយហត់ ដោយអស់ទាំងបញ្ញា និងស្មារតី។ លោកអ្នកមានគុណ ថែមទាំងផ្តល់នូវកម្លាំងចិត្ត ដល់កូនប្រកបដោយគុណធម៌ និង ទឹកចិត្តស្រលាញ់ចង់ឲ្យកូនល្អ តាំងពីកុមារភាព រហូតដល់រូបកូនបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និង កំពុងអភិវឌ្ឍ ក៏ដូចជាក្លាយខ្លួនទៅជាធនធានមនុស្សដ៏សំខាន់ដ៏សង្គមជាតិ។

ឆ្លៀតឱកាសនេះខ្ញុំ សូមថ្លែងអំណរគុណដល់ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការបណ្តុះបណ្តាល ចែករំលែក ព្រមទាំងផ្តល់ នូវការអប់រំ ចំណេះដឹង បទពិសោធន៍ និង ដំបូន្មានដ៏ល្អជាច្រើន រួមទាំងការណែនាំ បង្ហាត់បង្រៀន ដល់រូបខ្ញុំ យ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីឱ្យខ្ញុំបានសិក្សារៀនសូត្រ ក្រេបយកចំណេះវិជ្ជា រហូតដល់បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

ខ្ញុំបាទក៏ សូមថ្លែងអំណរអរគុណដល់ លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ្ត ដែលជាសាស្ត្រាចារ្យណែនាំរបស់រូបខ្ញុំផ្ទាល់លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីដឹកនាំ ផ្តល់ការប្រឹក្សា និង កែតម្រូវនូវរាល់ចំណុចខ្វះខាតទៅលើការស្រាវជ្រាវ និង ចងក្រងកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើម រហូតមកដល់ពេលដែលខ្ញុំ បានបញ្ចប់ និង សម្រេចបាននូវកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះដោយទទួលបាននូវលទ្ធផលល្អប្រសើរ។

ជាចុងបញ្ចប់ ដើម្បីជាកិច្ចតបស្នង និង ការដឹងគុណ ខ្ញុំបាទមានតែសូមជូនពរដល់ លោកអ្នកមានគុណ លោក លោកស្រី និង សាស្ត្រាចារ្យទាំងអស់ ឱ្យជួបតែសំណាងល្អគ្រប់ពេលវេលា ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន ជោគជ័យគ្រប់ភារកិច្ច និង សូមប្រសិទ្ធិពរជ័យ សិរីមង្គល បវរមហាប្រសើរ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបទក្រោមចំណងជើងថា “ **ការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដី** ’’ ត្រូវបានស្រាវជ្រាវ និងរៀបចំឡើងសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

ការជ្រើសរើសប្រធានបទសារណា “ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដី ’’ នេះគឺមិនមែនជា រឿងចៃដន្យនោះទេ ប៉ុន្តែក្រោយពីឆ្លងកាត់ការសិក្សាអស់រយៈពេលជិតបួនឆ្នាំនេះខ្ញុំយល់ឃើញថា ប្រធានបទសារណានេះគឺសមប្រកបសម្រាប់បរិបទសង្គមប្រទេសកម្ពុជាដែលប្រកាន់យកប្រព័ន្ធ សេដ្ឋកិច្ចទីផ្សារសេរី ហើយដែលវិស័យអចលនវត្ថុ បាននឹងកំពុងតែមានការរីកចម្រើនយ៉ាងខ្លាំង។ ម្យ៉ាងទៀត សេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្មរបស់ពលរដ្ឋក្នុងសង្គម បានបង្កើតឲ្យមាននូវចង្កោមនៃទំនាក់ទំនងគតិយុត្តស្មុគស្មាញជាច្រើនបណ្តាលឲ្យមានការប៉ះពាល់នូវផលប្រយោជន៍ ដែលកើតចេញពីបុគ្គលឯកជន។ ដើម្បីទប់ស្កាត់នូវហានិភ័យ ក៏ដូចជាដើម្បីផ្តល់ភាពយុត្តិធម៌ដែលអាច នឹងកើតមានជាយថាហេតុមិនអាចស្តារឡើងវិញបាននោះ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដី គឺជាយន្តការមួយដ៏ប្រសើរបំផុតសម្រាប់ការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលឯកជនទាំងនោះ ជាក់ស្តែងសង្កេតឃើញថានាពេលបច្ចុប្បន្នវិស័យសំណង់ដែលរីកដុះដាលយ៉ាងឆាប់រហ័ស ព្រមទាំងទីផ្សារនៃការសាងសង់សំណង់ជាច្រើន គឺបាននឹងកំពុងមានការប្រកួតប្រជែងគ្នា ជាហេតុធ្វើអោយសំណង់ជាប់នឹងដីមួយចំនួនមានការកិបកេង និងមិនបានគោរពទៅតាមបទដ្ឋានបច្ចេកទេសនៃសំណង់អោយបានភ្ជាប់ភ្ជួន ព្រមទាំងអំពើកើតចេញពីការធ្វេសប្រហែសផង នាំឲ្យបង្កនូវគ្រោះថ្នាក់ដល់ជនរងគ្រោះផ្ទាល់។

ដូច្នេះហើយខ្ញុំសង្ឃឹមថា ស្នាដៃនេះនឹងចូលរួមជាវិភាគទានដល់ការការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលឯកជន និងធានារក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម។

ជាចុងក្រោយនេះ ខ្ញុំសូមអភ័យទោសនូវកំហុសឆ្គងពាក្យពេជន៍ អក្ខរាវិរុទ្ធមួយចំនួន ឬរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី ខ្ញុំរីករាយទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាដើម្បីឲ្យសារណានេះកាន់តែមានភាពល្អប្រសើរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**........................................................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃអំពើអនីត្យានុកូលដែលបង្កឡើងនៃសំណង់ជាប់នឹងដី

**១.១ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល**........................................................................ ៤

១.១.១ លក្ខខណ្ឌនៃអំពើអនីត្យានុកូលទូទៅ ........................................................................៤

១.១.២ ការរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ........................................................................ ៧

**១.២ សញ្ញាណទូទៅនៃសំណង់ជាប់នឹងដី** ........................................................................ ៩

១.២.១ ប្រភេទនៃសំណង់........................................................................ ១១

១.២.២ ផ្នែកដែលចាត់ទុកជាសំណង់ ........................................................................ ១១

## ជំពូកទី២

## ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃសំណង់ជាប់នឹងដី

**២.១. ការទទួលខុសត្រូវអំពើអនីត្យានុកូលលើសំណង់ជាប់នឹងដីក្នុងពេលសាងសង់**....... ១៣

២.១.១. ភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្ម ........................................................................ ១៣

២.១.១.១ រូបវន្តបុគ្គល........................................................................ ១៣

២.១.១.២ នីតិបុគ្គល........................................................................ ១៥

**២.២. ការទទួលខុសត្រូវអំពើអនីត្យានុកូលលើសំណង់ជាប់នឹងដីក្រោយពេលសាងសង់**. ១៦

២.២.១. ភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្ម........................................................................ ១៧

២.២.១.១ អ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់ ........................................................................ ១៧

២.២.១.២ កូនជាង ឬកម្មករសំណង់........................................................................ ១៧

២.២.១.៣ កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ........................................................................ ១៨

២.២.១.៤. អ្នកគ្រប់គ្រងសំណង់ ........................................................................ ១៩

**២.៣. លក្ខខណ្ឌនៃការទទួលខុសត្រូវលើករណីនីមួយៗនៃសំណង់ជាប់នឹងដី ....................២០**

២.៣.១ ករណីមានអគ្គីភ័យ ....................២០

២.៣.១.១ អគ្គីភ័យបង្កដោយម្ចាស់កម្មសិទ្ធិករ....................២១

២.៣.១.២ អគ្គីភ័យបង្កដោយអ្នកមានសិទ្ធិគ្រប់គ្រងជំនួស....................២១

២.៣.២ ប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់....................២១

២.៣.៣ ការបាក់បែក ខូចទ្រង់ទ្រាយ ឬរលុំសំណង់ ....................២២

២.៣.៤. វិការៈនៃគុណភាពសំណង់ ឬការគ្រប់គ្រង....................២២

២.៣.៥ ការខូចខាតដោយសារករណីផ្សេងៗទៅដល់បុគ្គលដំទៃ....................២៣

**២.៤. លក្ខខណ្ឌដែលរួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលជាប់នឹងដី....................២៣**

២.៤.១ ការយល់ព្រមពីជនរងគ្រោះ ឬជាកំហុសទាំងស្រុងរបស់ជនរងគ្រោះ ....................២៣

២.៤.២ អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផល ....................២៤

២.៤.៣ ការកំណត់ពេល អំឡុងពេលបង្កើត និងរលត់អានុភាពនៃកិច្ចសន្យាលើសំណង់ ....................២៤

២.៤.៤ អសមត្ថភាពនៃការទទួលខុសត្រូវ....................២៥

## ជំពូកទី៣

## ការទាមទារព្យសនកម្មដែលអាចកើតមានឡើង

**៣.១ ការទាមទារព្យសនកម្មក្រៅផ្លូវតុលាការ....................២៦**

៣.១.១ ការចរចា ....................២៧

៣.១.២ សន្ធានកម្ម ....................២៨

**៣.២. ការទាមទារព្យសនកម្មតាមផ្លូវតុលាការ....................២៩**

៣.២.១. ទម្រង់ពាក្យបណ្តឹង....................២៩

៣.២.១.១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគី....................៣០

៣.២.១.២. កម្មវត្ថុនៃបណ្តឹងការទាមទារ ....................៣០

៣.២.១.៣. អង្គហេតុនៃការទាមទារ ....................៣០

៣.២.១.៤. កាលបរិច្ឆេទនៃការប្តឹង ........................................................................ ៣១

៣.២.១.៥. ស្នាមមេដៃ ឬហត្ថលេខា........................................................................ ៣១

៣.២.២. ការដាក់ពាក្យបណ្តឹង........................................................................ ៣២

៣.២.២.១. សមត្ថកិច្ចសាលាជម្រះក្តី ........................................................................ ៣២

៣.២.២.២. ការបង់ពន្ធលើពាក្យសុំ ........................................................................ ៣២

៣.២.៣. អាជ្ញាយុកាលនៃសិទ្ធិទាមទារសំណងការខូចខាត........................................ ៣៣

**សេចក្តីសន្និដ្ឋាន**........................................................................ ៣៥

**អនុសាសន៍** ........................................................................ ៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ភាពរីកចំរើនឥតឈប់ឈររបស់កម្ពុជា ដែលជាប្រទេសប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ គោរពទៅលើសិទ្ធិសេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម និងសិទ្ធិក្នុងការធ្វើសកម្មភាពទាំងឡាយរបស់ពលរដ្ឋ រួមទាំងករណីសំណង់ជាប់នឹងដី គឺដើម្បីធានានូវគុណភាពជីវិត ព្រមទាំងទំនួលខុសត្រូវរបស់បុគ្គល និងនីតិបុគ្គលពាក់ព័ន្ធសំណង់ជាប់នឹងដី និងបានទទួលស្គាល់នូវរបបកម្មសិទ្ធិឯកជនថែម ទៀតផង។ ដើម្បីឆ្លើយតបទៅនឹងភាពរីកចំរើនឥតឈប់ឈរជាមួយនឹងការប្រែប្រួលស្ថានភាពសង្គម នយោបាយ រដ្ឋបានបង្កើតឲ្យមាននូវទំនើបកម្មគតិយុត្តឲ្យស្របទៅតាមស្ថានភាពជាក់ស្តែងរបស់ សង្គមក្នុងគោលបំណង ដើម្បីគ្រប់គ្រងទៅលើបណ្តាសកម្មភាពទាំងអស់ របស់ពលរដ្ឋប្រកបដោយ ប្រសិទ្ធភាពជានារក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ពីព្រោះការបង្កើតទំនាក់ទំនងគតិយុត្តក្នុងសកម្មភាពពាណិជ្ជកម្ម កាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធអាចបង្កើតឲ្យមានការខ្វែងគំនិតគ្នាខាងផ្នែកផលប្រយោជន៍ ការទទួលខុសត្រូវលើអំពើប្រព្រឹត្ត ដែលជាហេតុនាំឲ្យកើតមានជម្លោះ។

ហេតុដូច្នេះហើយទើប រដ្ឋាភិបាលបានអនុម័ត និងឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រ ដាក់ឱ្យប្រើប្រាស់នូវ ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧ ដោយក្នុងក្រមក៏បានចែងពីអំពើអនីត្យានុកូល និង ក្រមព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤, ២៧ ខែកក្កដា ឆ្នាំ ២០០៧ បានចែងពីការដាក់ទោសទណ្ឌដល់ចារី ទៅលើទង្វើដែលបានធ្វើតាមបទល្មើសនីមួយៗ ប៉ុន្តែការទទួលខុសត្រូវខាងព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរជាងរដ្ឋប្បវេណី ដោយសារចំពោះការទទួលខុសត្រូវ អាចត្រូវជាប់ពន្ធនាគារទៅតាមស្ថានទម្ងន់ទោសថេរវេលាវែង ខ្លី ឬអស់មួយជីវិត។ រីឯខាងរដ្ឋប្បវេណីវិញ អ្នកប្រព្រឹត្តត្រូវមានទំនួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់ខ្លួនបង្កតាមរយៈការសងព្យសនកម្មទៅជនដែលរងគ្រោះ ឬ អ្នករងគ្រោះ។

លើសពីនេះ ច្បាប់ស្តីពីសំណង់ លេខ នស/រកម/១១១៩/០១៩, ១៨ ខែតុលា ឆ្នាំ២០១៩បានអនុម័តឡើងដើម្បីរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គម គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន ក៏ដូចជា សោភណភាព និងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ ជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច និងសង្គម ហើយបានចែងពីការដាក់ទោស និងពិន័យដែលកើតចេញពីសំណង់ជាប់នឹងដី។ ដើម្បីទប់ស្កាត់នូវបញ្ហាផ្សេងៗដែលនឹងកើតមានឡើងជាយថាហេតុនោះ ទើបជម្រុញឲ្យមានការចូលរួមពីរាជរដ្ឋាភិបាលបានគិតគូរពីបញ្ហាទាំងឡាយដែលបង្កដោយសំណង់ឈានរហូតដល់ករណីមួយចំនួនកើតចេញពីការធ្វេសប្រហែស និងករណីផ្សេងៗទៀតបង្កឲ្យប្រជាពលរដ្ឋបាត់បង់អាយុជីវិត សោក

នាដកម្ម និងបង្កភាពរីករវក្នុងសង្គម។ ជាក់ស្តែងដូចករណីរលំអាគារកម្ពស់៧ជាន់ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយសារតែមើលឃើញថាករណីឧប្បទ្ទវហេតុបាក់រលំអាគារនេះបានបង្កនូវការខូចខាតយ៉ាងធំធេងបង្កដោយសំណង់ដែលជាករណីទី១ហើយសម្រាប់ប្រទេសកម្ពុជានាពេលនោះ។ ករណីនេះជាសោកនាដកម្មដែលបានបង្កឲ្យមនុស្សស្លាប់ និងរងរបួសជាច្រើននាក់ ព្រមទាំងបានបំផ្លិចបំផ្លាញនូវ ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ហើយក៏មានប៉ះពាល់ទៅដល់សំណង់ដ៏ទៃទៀតនៅក្បែរសំណង់អាគារដែលបានបាក់រលំ ដែលយើងគួរតែពិចារណាអំពីការទទួលខុសត្រូវក្នុងជួសជុលការខូចខាត។

ហេតុដូច្នេះហើយទើបបានជាខ្ញុំលើកយកប្រធានបទនេះមកធ្វើការស្រាវជ្រាវលើ ការបង្កការខូចខាតដោយសំណង់ចំពោះការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីគឺជាប្រធានបទមួយដែលសមស្របជាមួយបរិបទសង្គម និងការរីកចម្រើនឥតឈប់ឈរពាក់ព័ន្ធនឹងវិស័យសំណង់នៅប្រទេសកម្ពុជា ។ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដី គឺសំដៅលើសំណងនៃការខូចខាតដែលអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវទៅលើសំណង់ជាប់នឹងដី ហើយបើនិយាយពីអំពើអនីត្យានុកូល មិនមែនជាការទទួលខុសត្រូវដែលកើតចេញពីកំហុសដោយផ្ទាល់ពីអ្នកបង្កឡើយ។ ពោលគឺរាល់ការខូចខាតដែលអាចកើតមានឡើងបានក៏ស្តែងចេញពី ទ្រព្យសម្បត្តិ ឬការគ្រប់គ្រងផងដែរក្នុងការទទួលខុសត្រូវ ដូចករណីសំណង់ជាប់នឹងដីខាងលើ។

ដែនកំណត់ក្នុងការស្រាវជ្រាវសារណានេះ គឺខ្ញុំបានកំណត់ត្រឹមការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កឡើងដោយសំណង់ជាប់នឹងដីដែលបង្ហាញពីការទាក់ទងទៅនឹងរដ្ឋប្បវេណី ប៉ុណ្ណោះ។ រីឯ ច្បាប់ដែលពាក់ពន្ធ័ទៅនឹងសំណង់ជាប់នឹងដីផ្សេងៗទៀត ខ្ញុំមិនបានផ្តោត និងលើកយកមកអធិប្បាយឱ្យបានក្បោះក្បាយនោះទេ។

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺចង់បង្ហាញក្របខណ្ឌច្បាប់ដែលត្រូវបានអនុវត្ត ចំពោះអំពើអនីត្យានុកូលដែលពាក់ព័ន្ធនឹងសំណង់ជាប់នឹងដី ការសិក្សាពីកម្រិតនៃការទទួលខុសត្រូវរបស់ភាគីដែលពាក់ព័ន្ធ និងទៅតាមករណីតែងតែជួបប្រទះជារឿយៗនៅក្នុងសង្គមដោយសង្កេតឃើញមានការវែកញែកដេញដោលទៅលើការទទួលខុសត្រូវ ព្រមទាំងល័ក្ខខ័ណ្ឌទៅតាមករណីនីមួយៗដែលរួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃសំណង់ជាប់នឹងដី។

ដូច្នេះ តើសញ្ញាណទូទៅនៃអំពើអនីត្យានុកូល ក៏ដូចជាបង្កដោយសំណង់ជាប់នឹងដីអ្វី? ហើយអំពើអនីត្យានុកូល អាចចាត់ចូលបានក្រោមទម្រង់ណាខ្លះ? តើភាគីណាខ្លះដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក្នុងពេលសាងសង់ និងក្រោយពេលបញ្ចប់សាងសង់? តើនរណាខ្លះដែលត្រូវរ៉ាប់រងលើព្យសនកម្មទៅតាមករណីនីមួយៗ និងល័ក្ខខ័ណ្ឌដែលចាត់ចូលជាការរួចផុតពីការទទួលខុសត្រូវ?

ដើម្បីឆ្លើយនឹងសំនួរខាងលើនេះ ខ្ញុំសូមធ្វើការបកស្រាយក្នុងប្រធានបទសារណានេះដោយធ្វើការបែងចែកជាបីផ្នែកធំៗ ដូចខាងក្រោម៖

- ជំពូកទី១ សញ្ញាណទូទៅនៃអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដី ។
- ជំពូកទី២ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃសំណង់ជាប់នឹងដី ។
- ជំពូកទី៣ ការទាមទារព្យសនកម្មដែលអាចកើតមានឡើង ។

# ជំពូកទី១
# សញ្ញាណទូទៅនៃអំពើអនីត្យានុកូលដែលបង្កឡើងនៃសំណង់ជាប់នឹងដី

ចំពោះសំណង់ជាប់នឹងដីឃើញថាការបង្កឡើងដោយអំពើអនីត្យានុកូល ដោយក្នុងនោះមានការបញ្ញត្តិនានាឡើងពីសញ្ញាណនៃអំពើអនីត្យានុកូល។

## ១.១ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល

យោងទៅតាមក្រមរដ្ឋប្បវេណី អំពើអនីត្យានុកូល សំដៅទៅដល់អំពើបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬដោយអចេតនា។ ក្នុងន័យនេះជនណាបានប្រព្រឹត្តិត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយសារអំពើនោះ។[1] អំពើអនីត្យានុកូល ជាប្រភពនៃកាតព្វកិច្ចមួយដែលកើតឡើងក្រៅឆន្ទៈរបស់ភាគីនៃកាតព្វកិច្ច ឬជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់។[2] ក្នុងន័យខាងលើផងដែរ ក៏អាចបញ្ជាក់បានទៅលើអំពើអនីត្យានុកូល ជាប្រភេទមួយនៃព្រឹត្តិការណ៍តាមលក្ខណៈគតិយុត្តដោយតាមរយៈនេះបុគ្គលជាចារីបានបំពានសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ។ ដោយការបំពាននោះទៀតសោតគឺរាប់បញ្ចូលទាំងអំពើដែលសកម្ម ឬ អំពើអកម្មក្តី។ ការនាំឲ្យមានការទទួលខុសត្រូវក្នុងអំពើអនីត្យានុកូលនេះដោយសារគោលការណ៍ទូទៅនៃការទទួលខុសត្រូវដោយមានកំហុសកើតឡើង។

តាមនិយមន័យ ដែលមានចែងក្នុងច្បាប់ កាតព្វកិច្ចមានន័យថា ជាទំនាក់ទំនងគតិយុត្តិដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល។[3]

### ១.១.១ លក្ខខណ្ឌនៃអំពើអនីត្យានុកូលទូទៅ

ក្នុងការបង្ហាញនៃអំពើអនីត្យានុកូលដែលមានលក្ខណៈតាមច្បាប់ គឺបានសបញ្ជាក់ដោយផ្តោតសំខាន់ទៅលើកាតព្វកិច្ចដែល បុគ្គលរូបណាត្រូវចូលមកទទួលខុសត្រូវលើទង្វើដែលបានកើតមានឡើង ក្នុងន័យការពារ ផ្តល់ជាមធ្យោបាយដល់ជនរងគ្រោះ អាចទាមទារសំណងខូចខាតបានពីចារី។ ម្យ៉ាងវិញទៀត កម្មវត្ថុនៃសំណងនៃការខូចខាតមិនត្រឹមតែមានការខូចខាតផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទេ ប៉ុន្តែរួមមានទាំងការខូចខាតខាងផ្លូវចិត្តជនរងគ្រោះទៀតផង។ ទោះជាមានឆ្លុះបង្ហាញពីគោលបំណងនៃអំពើអនីត្យនុកូលក៏ដោយ ដើម្បីអាចកំណត់បានថាចាត់ចូលជាល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល យោងតាមក្របរដ្ឋប្បវេណី បានតាក់តែងផងដែររួម

---

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៤៣ វាក្យខណ្ឌទី១។

[2] ក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៣០៨ វាក្យខណ្ឌទី១ និងទី២។

មាន ដូចជា[4] ៖ កំហុស(១.១.១.១) ភាពខុសច្បាប់(១.១.១.២) ការខូចខាត(១.១.១.៣) ទំនាក់ទំនងហេតុផល រវាងអំពើបំពាន និងការខូចខាត(១.១.១.៤)។

### ១.១.១.១ កំហុស

ទម្រង់នៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទូទៅ មិនមែនតម្រូវឱ្យមានតែការកើតឡើងនូវការខូចខាតតែប៉ុណ្ណោះទេ គឺតម្រូវឱ្យមានកំហុសចេតនា ឬអចេតនា ថែមទៀត។

អត្ថន័យនៃកំហុស គឺបង្ហាញទៅលើទង្វើដែលខ្លួនបានធ្វើស្តែងចេញអំពីអាកប្បកិរិយារបស់អ្នកប្រព្រឹត្ត ដែលការមិនការយកចិត្តទុកដាក់ មានការធ្វេសប្រហែសទៅលើកាតព្វកិច្ច ឬករណីកិច្ចរបស់ខ្លួនដោយធ្វើអោយអ្នកដទៃទទួលរងការខូចខាត ឬអាចប្រព្រឹត្តដោយមិនបានស្តែងចេញពីបំណងលើជនរងគ្រោះ។ ហេតុដូចនេះទើបកំហុសត្រូវបានច្បាប់បែងចែកចេញជា ពីរ គឺ កំហុសចេតនា និងកំហុសអចេតនា។

#### ក. កំហុសចេតនា

កំហុសចេតនា មានន័យថា នៅពេលដែលប្រព្រឹត្តអំពើអ្វីមួយ ជននោះយល់ដឹង ឬ ព្យាករបានថាអំពើរបស់ខ្លួននឹងបង្កើតឱ្យមានលទ្ធផល គឺការអន្តរាយដល់ជនដទៃ ហើយខ្លួនព្រមទទួលយកការកើតឡើងនូវលទ្ធផលនោះ ទោះបីជាគោលដៅនៃអំពើមិនប្រាកដថាត្រូវបង្កឱ្យមានអន្តរាយក្តី។

កំហុសចេតនា ក៏ចាត់ទុកជាកំហុសដែលចារីបង្កើតឡើងពីឆន្ទៈ ហើយចង់បង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ កំហុសនេះអាចជាទង្វើបង្កជាបទល្មើសព្រហ្មទណ្ឌ ឬ ជាទង្វើដែលមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែរ។[5]

#### ខ. កំហុសអចេតនា

កំហុសអចេតនា មានន័យថាជា កំហុសដែលកើតឡើងដោយសារ ការធ្វេសប្រហែស ការខ្ជីខ្ជា ឬការខ្វះការប្រុងប្រយ័ត្នរបស់ចារីនៃការខូចខាត។ឧទាហរណ៍៖ កំហុសរបស់ម្ចាស់កម្មសិទ្ធិករដែលធ្វេសប្រហែសមិនប្រុងប្រយ័ត្នខ្វះការគ្រប់គ្រងធ្វើអោយផ្នែកណាមួយនៃសំណង់ជាប់នឹងដីរបស់ខ្លួន បង្កឱ្យមានការប៉ះពាល់ទៅដល់អ្នកដទៃ។

ក្នុងន័យនេះ កំហុសអចេតនាគឺ ជនដែលបានបង្កមិនមានការតាំងចិត្ត ឬមានបំណងដើម្បីអោយអ្នកដទៃទទួលរងគ្រោះនោះទេ ពោលគឺចេញឡើងដោយការចៃដន្យ ឥតបានព្រៀងទុកជាមុន។

### ១.១.១.២ ភាពខុសច្បាប់

ភាពខុសច្បាប់ គឺជាអំពើដែលបំពានសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ ហើយបង្កឱ្យមានការអន្តរាយដោយសារតែអំពើនោះ ឬជាការប្រើប្រាស់សិទ្ធិដោយបំពាន ជាអាទិ៍។ សកម្មភាពខុសច្បាប់នៅត្រង់នេះ មិនមែន

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៤៣។

[5] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពី អំពើអនីត្យានុកូល, ៦៩។

សំដៅតែលើការបំពានច្បាប់ព្រហ្មទណ្ឌនោះឡើយ។ ជាទូទៅ បុគ្គលម្នាក់ៗមិនអាចធ្វើសកម្មភាពបំពានលើសិទ្ធិ ឬប្រយោជន៍របស់អ្នកដទៃឡើយ។ ដូចនេះរាល់សកម្មភាពបំពានសិទ្ធិ ឬប្រយោជន៍ គឺជាការបំពានដោយខុសច្បាប់។ លើកលែងតែការបំពានដោយមានសិទ្ធិ ឬច្បាប់អនុញ្ញាត ដោយច្បាស់លាស់ ដូចជា៖ ករណីឪពុកម្ដាយវាយប្រដៅកូន។

ភាពបំពានលើបទបញ្ញត្តិ ក៏ជាការបំពានសិទ្ធិ និងផលប្រយោជន៍របស់អ្នកដទៃដែលត្រូវបាន ការពារដោយច្បាប់។ ជាក់ស្ដែងសកម្មភាពនៃការបំពាន អាចស្ដែងចេញតាមរូបភាព ២ (ពីរ) យ៉ាង។ រូបភាពទី១ គឺជាសកម្មភាពជាក់ស្ដែងក្នុងការប្រព្រឹត្ត ហើយក្នុងការប្រព្រឹត្តឡើងពីជនបង្កទៀតសោត ក៏បានស្ដែងចេញពីឆន្ទៈ ឬតាមមធ្យោបាយណាមួយ។ រូបភាពទី២៖ គឺជារូបភាព អកម្ម ដោយបុគ្គលនោះមិនធ្វើអំពើណាមួយដែលជាកាតព្វកិច្ចរបស់ខ្លួន ឬជាការកំណត់របស់ច្បាប់ បណ្ដាលឱ្យខូចខាតផលប្រយោជន៍របស់អ្នកដទៃ។[6]

លើសពីនេះទៅទៀត យោងតាមមាត្រា ៧៤៣ ត្រង់កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីបានចែងថា “*បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬកំហុសអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ*” ។

ការបំពានលើសិទ្ធិ ឬប្រយោជន៍ គឺបុគ្គលគ្រប់រូប មានសេរីភាពក្នុងការធ្វើសកម្មភាពនានា លើកលែងតែសកម្មភាពនោះបានបង្កឲ្យមានការខូចខាតដល់អ្នកដទៃ។

កាលណា បានបង្កឲ្យមានការខូចខាតដល់អ្នកដទៃ សកម្មភាពនោះនឹងក្លាយជាសកម្មភាពបំពានសិទ្ធិ ឬប្រយោជន៍ ដែលត្រូវសងការខូចខាត កាលណាវាបានបំពេញនូវល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល។

**១.១.១.៣ ការខូចខាត**

ការខូតខាត ឬព្យសនកម្ម បើទោះបីជាមានអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃក្ដី ប្រសិនបើពុំមានព្យសនកម្មកើតឡើងទេ គឺគ្មានការទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះទេ។ ត្រង់នេះក៏ចាត់ចូលជាចំណុចសំខាន់មួយ ដោយការខូចខាតត្រូវបានបែងចែកជា ២ (ពីរ) [7] គឺការខូចខាតជាទ្រព្យសម្បត្តិ និងការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ។

**ក. ការខូចខាតផ្នែកទ្រព្យសម្បត្តិ**

ការខូចខាតផ្នែកទ្រព្យសម្បត្តិ ឬការខូចខាតខាងសម្ភារ ជាការខូចខាតទាំងឡាយណាដែលប៉ះពាល់បែកបាក់វត្ថុ ខូចខាតដល់ទ្រង់ទ្រាយ ឬបំពានទៅដល់បេតិកភណ្ឌរបស់បុគ្គលណាមួយ ដែលស្ថិតក្រោមរូបភាព

[6] លោក អ៊ីវ ប៉ូលី, អំពើអនីត្យានុកូល, ៥។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៤៤។

ជាទ្រព្យសម្បត្តិរបស់បុគ្គលនោះ ដូចជា ការបាត់បង់វត្ថុ ការរលុំបាក់បែករបស់សំណង់ឬមួយផ្នែកនៃសំណង់ ដែលបង្កការខូចខាត ទៅលើសំណង់ជាកម្មសិទ្ធិរបស់បុគ្គល ឬនីតិបុគ្គលដ៏ទៃទៀត ។

**ខ. ការខូចខាតមិនមែនជាទ្រព្យសម្បត្តិ**

ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ ជាការខូចខាតទៅលើ រូបរាងកាយ និងស្មារតី ។ ហើយការខូចខាតទៅលើរូបរាងកាយ និងស្មារតី គឺ ដោយបានបង្កតាមរយៈការបំពាន ឬប៉ះពាល់ទៅដល់ជនដទៃ ធ្វើអោយមានរបួសស្នាម ការឈឺចាប់ ឬអាចឈានទៅដល់អាយុជីវិតរបស់ជនរងគ្រោះ។

ការខូចខាតមិនមែនជាទ្រព្យសម្បត្តិ អាចការខូចខាតខាងផ្លូវចិត្ត ឬ ការខូចខាតសតិអារម្មណ៍។ ដូចជា ការខូចខាតលើកេរ្តិ៍ឈ្មោះ កិត្តិយស របស់ជនរងគ្រោះដែលបណ្តាលមកពីការបរិហារកេរ្តិ៍ ជាដើម។

**១.១.១.៤ ទំនាក់ទំនងហេតុផលរវាងអំពើបំពាន និងការខូចខាត**

ទំនាក់ទំនងនៃហេតុផល មានន័យជាទំនាក់ទំនងនៃហេតុផល នៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និងចេតនា និងកំហុសរបស់ចារី ដែលចាំបាច់ត្រូវមានអត្ថិភាពនៃទំនាក់ទំនងហេតុផល ដើម្បីកំណត់ថា ចារីបានបង្កឱ្យមានការខូចខាតដល់ជនរងគ្រោះ។ ដើម្បីទាមទារសំណងការខូចខាតពីចារី អ្នកទាមទារសំណងការខូចខាតត្រូវបង្ហាញថា ការខូចខាតពិតជាកើតចេញពីអំពើបំពាន មានន័យថា ការខូចខាតមានទំនាក់ទំនងទៅនឹងអំពើបំពាន។ ផ្ទុយទៅវិញ ប្រសិនបើការខូចខាតមិនបានកើតចេញពីអំពើបំពានទេ ជនរងគ្រោះ ឬ ង្អករងគ្រោះ មិនអាចទាមទារសំណងបានឡើយ។

**១.១.២ ការរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល**

អំពើអនីត្យានុកូលទោះជាច្បាប់បានកំណត់ នៅអ្នកដែលបានប្រព្រឹត្តត្រូវទទួលខុសត្រូវលើសំណង ដែលបានប្រព្រឹត្តក៏ដោយ ប៉ុន្តែក៏មានល័ក្ខខ័ណ្ឌដែលបានផ្តល់នូវផលប្រយោជន៍ទៅឱ្យអ្នកប្រព្រឹត្តអំពើបំពានផងដែរ ដូចជា សមត្ថភាពនៃការទទួលខុសត្រូវ(១.១.២.១) ការការពារជាធម្មានុរូប(១.១.២.២) ស្ថានភាពចាំបាច់(១.១.២.៣) ការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីជនរងគ្រោះ(១.១.២.៤) និង សង្គមទទួលស្គាល់ថាសមហេតុផល(១.១.២.៥) ។

**១.១.២.១ សមត្ថភាពនៃការទទួលខុសត្រូវ**

សមត្ថភាពនៃការទទួលខុសត្រូវគឺជា ល័ក្ខខ័ណ្ឌមួយទៀតក្នុងការឱ្យបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល។ អ្នកប្រព្រឹត្តអំពើអនីត្យានុកូល ត្រូវទទួលខុសត្រូវសងការខូចខាត ដែលកើតចេញពីអំពើបំពានរបស់ខ្លួន លើកលែងតែជនដែលបានបង្កនោះជាជនដែលច្បាប់ចាត់ទុកជាអនីតិជនអាយុក្រោម ១៤ ឆ្នាំនិងជនដែលមិនអាចយល់ដឹង ដោយវិបត្តិស្មារតី ឬ ដោយសារមូលហេតុផ្សេងៗទៀតមិនត្រូវទទួលខុសត្រូ

ចំពោះអំពើអនីត្យានុកូលឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តឡើយប្រសិនបើករណីនោះជាករណីដែលស្ថានភាពនោះបណ្តាលមកដោយកំហុសចេតនា ឬដោយកំហុសអចេតនា។[8]

លើសពីនេះ ការរួចផុតពីការទទួលខុសត្រូវសងការខូចខាត មានន័យថាមានអំពើអនីត្យានុកូល ប៉ុន្តែមានហេតុដែលនាំឲ្យអ្នកប្រព្រឹត្តអំពើអនីត្យានុកូលនោះ មិនទទួលខុសត្រូវសងការខូចខាតឡើយ។ តួយ៉ាងដូចបានកំណត់នៃការរួចផុតទទួលខុសត្រូវមាន៖

**១.១.២.២ ការការពារជាធម្មានុរូប**

ការការពារជាធម្មានុរូប គឺជាអំពើរំលោភបំពានដែលមិនអាចជៀសវាងបានដើម្បីការពារខ្លួន ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ចំពោះអំពើបំពានដោយមិនត្រឹមត្រូវ ស្ថិតនៅក្នុងករណីដែលអំពើបំពាន និងអំពើរំលោភនោះស្ថិតនៅជិតគ្នានិងមានកម្រិតតុល្យភាពគ្នារវាងការការពារ និងការបំពាន។[9]

កិច្ចការពារជាធម្មានុរូបពុំត្រូវបានចាត់ទុកថាជាអំពើបំពានដោយ ខុសច្បាប់ឡើយ ដោយហេតុថា បុគ្គលដែលបានប្រព្រឹត្តអំពើនេះត្រូវបានច្បាប់ អនុញ្ញាតដើម្បី កុំឱ្យមានព្យសនកម្មធ្ងន់ធ្ងរកើតមានឡើង។

**១.២.២.៣ ស្ថានភាពចាំបាច់**

ស្ថានភាពចាំបាច់ សំដៅទៅលើអំពើរំលោភបំពានដែលមិនអាចជៀសវាងបាន ហើយដើម្បីការពារខ្លួន ឬទ្រព្យសម្បត្តិខ្លួន ឬអ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន ដែលស្ថិតនៅក្នុងករណីមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។[10]

**១.២.២.៤ ការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីជនរងគ្រោះ**

មូលហេតុផ្សេងទៀត អំពើដែលបង្កឱ្យមានការអន្តរាយក្នុងករណីដែលមានការយល់ ព្រមពីសំណាក់ជនរងគ្រោះ ទោះបីជាស្វ័យភាពនៃបុគ្គលជនក៏ពិតមែន ប៉ុន្តែដើម្បីឲ្យសង្គមមានសណ្តាប់ធ្នាប់ មិនអាណាធិបតេយ្យ ឆន្ទៈរបស់បុគ្គលឯកជនក៏ត្រូវមានកម្រិតដែរ។

ទោះបីជាក្នុងករណីដែលជនរងគ្រោះយល់ព្រមលើអំពើបំពាន ឬទទួលយកគ្រោះថ្នាក់ ប៉ុន្តែសង្គមមិនទទួលថាសមហេតុផល នោះការយល់ព្រមរបស់ជនរងគ្រោះ មិនមែនជាហេតុផលនាំឲ្យអ្នកប្រព្រឹត្តអំពើបំពានរួចផុតពីការទទួលខុសត្រូវឡើយ។ ដូចជាយល់ព្រមទទួលយកគ្រោះថ្នាក់ពីការលក់អវយវៈជាដើម។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៤៥។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៥៥។

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៥៥។

#### ១.២.២.៥ សង្គមទទួលស្គាល់ថាសមហេតុផល

ប្រសិនបើសង្គមទទួលស្គាល់នូវអំពើបំពានណាផ្សេងទៀត ថាសមហេតុផលក្នុងការប្រព្រឹត្ត នោះអ្នកប្រព្រឹត្តអំពើបំពាននោះមិនទទួលខុសត្រូវក្នុងការសងការខូចខាតឡើយ។

អំពើរបស់មន្ត្រី រាជការដែលទទួលនូវការអនុវត្តសិទ្ធិអំណាចសាធារណៈ របស់រដ្ឋ ដែលបង្កឱ្យមានការខូចខាតដល់អ្នកដទៃ ដោយគ្មានកំហុសក្នុងការអនុវត្តភារកិច្ច មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ដូចជា ការអនុវត្តសាលក្រម ជាអាទិ៍។ ការអនុញ្ញាតរបស់រដ្ឋ ឬច្បាប់ ទៅតាមស្ថានភាពជាក់ស្តែងនៃសកម្មភាពនោះ ដូចជា ការធ្វើកូដកម្ម ឬបាតុកម្ម ទោះបីជាប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ ក៏មិនទទួលនោះទេ។

វាប្រែប្រួលទៅតាមគំនិតនៃមនុស្សទូទៅដែលរស់នៅក្នុងសង្គមដោយមិនអាចកំណត់ច្បាស់លាស់ថាអំពើបំពានណាមួយដែលសង្គមទទួលស្គាល់ថាសមហេតុនោះឡើយ។ ដូចជា ការវាយប្រដៅសិស្សជាដើម។

## ១.២ សញ្ញាណទូទៅនៃសំណង់ជាប់នឹងដី

នៅគ្រប់សម័យកាល សំណង់បានចូលរួមចំណែកដែលមិនអាចខ្វះបានសំរាប់ផ្តល់នូវជម្រកសម្រាប់មនុស្សជាតិយើង ហើយមិនត្រឹមតែសំណង់ជាជម្រកស្នាក់អាស្រ័យតែមួយមុខនោះទេ សំណង់បានផ្តល់នូវផលប្រយោជន៍ដទៃទៀត ដូចជាផ្តល់នូវសោភណ៍ភាព បង្ហាញពីអរិយធម៌ជាដើមរបស់សង្គមជាតិនិមួយៗ។

សំណង់ សំដៅទៅដល់ដំណើរការនៃការងារសំណង់ ដល់អាគារ គ្រឿងផ្គុំ ស្ថាបត្យការ្យទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។[11] រីឯសំណង់ជាប់នឹងដីត្រូវបានបកស្រាយ ក្នុងន័យទូលាយរួមមាន ផ្ទះ អាគារ ឃ្លាំង ស្ពាន ផ្លូវដែក បង្គោលភ្លើង បង្គោលអង់តែន ពោលគឺគ្រប់សំណង់ដែលភ្ជាប់នឹងដីទាំងអស់ ។[12]

លើសពីនេះទៅទៀត សំណង់ ក៏ត្រូវបានចាត់ទុកជាផ្នែកមួយនៃផលិតផលគ្រឹះក្នុងខឿនសេដ្ឋកិច្ចជាតិដោយសំណង់មាន តួនាទីសំខាន់ ក្នុងការកសាងមូលដ្ឋានសម្ភារ បច្ចេកទេសសង្គម សំខាន់ចំពោះកម្ពុជាដែលកំពុងកសាងខឿនសេដ្ឋកិច្ចជាតិតាមទិសដៅសេដ្ឋកិច្ចសេរី។ ផលិតផលសំណង់មានទំនាក់ទំនងជាមួយនិងផ្នែកផលិតផលទាំងអស់ ហើយជាមួយវិស័យសេដ្ឋកិច្ច គ្រប់ផ្នែកក្នុងរយៈកាលអភិវឌ្ឍន៍ដំបូង ពោលគឺសំដែងចេញនូវការអភិវឌ្ឍន៍របស់សង្គម។ ដោយហេតុនេះ រដ្ឋាភិបាលបានហៅសំណង់ ជាមុខរបរឧស្សាហកម្មធន់ធ្ងន់មួយក្នុងចំណោម ឧស្សាហកម្មធន់ធ្ងន់ដទៃទៀត។[13]

[11] សន្ធានុក្រមនៃច្បាប់ស្តីពីសំណង់,២០១៩។

[12] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពី អំពើអនីត្យានុកូល, ៨៩។

[13] លោក សួស ចំរើន, គ្រប់គ្រងសំណង់ ២០០៣។

### ១.២.១ ប្រភេទនៃសំណង់

សំណង់ជាប់នឹងដី មានការចែកចេញជាច្រើនទម្រង់តាមការងាររចនាឡើងរបស់អ្នកសាងសង់ ឬតាមតម្រូវការ ដូចជាទៅតាមស្ថានភាពលក្ខណៈភូមិសាស្ត្រនៅតាមតំបន់នីមួយៗ។ ជាក់ស្តែងនៅក្នុងប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ បានឲ្យនិយមន័យ អាគារនិងសំណង់ផ្សេងៗ គឺសំដៅដល់អាគារ និងសំណង់ផ្សេងៗដែលសង់ជាប់នឹងដីទោះបីមាន ឬគ្មានជញ្ជាំង ឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារ អាផាតមែន ខុនដូ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អាគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គីសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។

ទោះបីជាសំណង់ជាប់នឹងដី ជាសំណង់ទាំងអស់ដែលស្ថិតនៅជាប់នឹងដីក៏ពិតមែន ប៉ុន្តែសំណង់ជាប់នឹងដី អាចត្រូវបានសំដៅដល់ជា ៣ (បី) ផ្នែក គឺសំណង់ឥដ្ឋបេតុង(១.២.១.១) សំណង់មិនមែនជាឥដ្ឋបេតុង (១.២.១.២) និងគ្រឿងនៃអាគារ ផ្លាក វត្ថុតុបតែង ជាសមាសភាពនៃអាគារ(១.២.១.៣) [14]។

#### ១.២.១.១ សំណង់ឥដ្ឋបេតុង

សំណង់ឥដ្ឋបេតុង គឺជាសំណង់ទាំងឡាយណាដែលសាងសង់ឡើងផ្អែកទៅលើបច្ចេកទេសមួយបែបដោយមានការប្រើប្រាស់នូវរូបធាតុដូចជា ការប្រើនូវឥដ្ឋដើម្បីបម្រើដល់ការសាងសង់សំណង់ ព្រមទាំងគួបផ្សំជាមួយនឹងបេតុង ចាក់បំពេញទៅនិងគ្រឿងបង្គុំ។ ជាទូទៅសំណង់ដែលប្រើប្រាស់រូបធាតុទាំងពីរខាងលើ គឺមានគុណភាពល្អ គង់វង្ស និងការឲ្យសំណង់សាងសង់បានច្រើនជាន់ ទៅតាមបរិបទ ហើយសំណង់ប្រភេទនេះអាចរាប់បញ្ចូលបានទាំងបម្រើដល់សេចក្តីត្រូវការរបស់មនុស្សជាតិ។

#### ១.២.១.២ សំណង់មិនមែនជាឥដ្ឋបេតុង

សំណង់មិនមែនជាឥដ្ឋបេតុង មានលក្ខណៈខុសពីសំណង់ឥដ្ឋបេតុង ត្រង់ថាសំណង់ប្រភេទនេះគឺបានរាប់បញ្ចូលគ្នាជាច្រើន ទៅនឹងបច្ចេកទេសផ្សេងៗ ដែលអាចជួយឲ្យការសាងសង់មានភាពរហ័សជាង និងអាចប្រើប្រាស់ច្រើនទៅតាមតម្រូវការ ដូចទៅនឹងសំណង់ធ្វើឡើងពីបេតុង ដោយមានដូចជា សំណង់ដែលធ្វើពី រូបធាតុដែក សំណ ឬរូបធាតុផ្សេងៗទៀត ដើម្បីសាងសង់បង្កើតជាសំណង់ជាប់នឹងដី មិនតែប៉ុណ្ណោះ សំណង់ធ្វើពីឈើ ក៏ត្រូវបានចាត់ទុកជាសំណង់មិនមែនជាឥដ្ឋបេតុងផងដែរ ។

#### ១.២.១.៣ គ្រឿងនៃអាគារ ផ្លាក វត្ថុតុបតែង ជាសមាសភាពនៃអាគារ

ចំពោះវត្ថុធាតុដែលជាសមាសភាគនៃអាគារ គ្រឿងអាគារ គ្រឿងសង្ហារិម ផ្លាកវត្ថុតុបតែង ជាអាទិ៍ ដែលមិនអាចបែងចែងបាន ដោយមិនបំបែកអាគារនោះ ឬដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុ

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ១២៥។

នោះជាសមាសភាពនៃអាគារ។ ហេតុដូចនេះសំរាប់គ្រឿងនៃអាគារ ផ្លាក វត្ថុតុបតែង ជាសមាសភាពនៃអាគារ ក៏ចាត់ទុកជាប្រភេទមួយនៃសំណង់ជាប់នឹងដីផងដែរ។

**១.២.២ ផ្នែកដែលចាត់ទុកជាសំណង់**

សំណង់ជាប់នឹងដី ទៅលើផ្នែកដែលចាត់ទុកជាសំណង់បានបង្កនូវលក្ខណៈប្រសើរ ដើម្បីអាចកំណត់សម្គាល់។ សំណង់ជាប់ដី បានចែកចេញជាច្រើនផ្នែក ទៅតាមការកំណត់តាមច្បាប់ដូចខាងក្រោមៈ[15]

សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់តិចជាង ឬលើសពី៥០០ (ប្រាំរយ) ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង ឬលើសពី ៤ (ជាន់)រួមទាំងជាន់ផ្ទាល់ដី និងមានគិតបញ្ចូលប្រសិនបើមានជាន់ក្រោមដីដែលមានជម្រៅទាបជាង ឬជ្រៅជាង ៥ (ម៉ែត្រ)។

របងថ្ម ឬបេតុង ឬមិនធ្វើពីថ្ម ឬបេតុងដែលមានកម្ពស់ទាបជាង ឬលើសពី៣ (បី) ម៉ែត្រ គឺត្រូវចាត់ទុកជាសំណង់ជាប់នឹងដី។

សំណង់ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាង ឬលើសពី៥ (ប្រាំ) ម៉ែត្រ

ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាង ឬលើសពី៥០០ (ប្រាំរយ) ម៉ែត្រក្រឡា។

អាងតម្កល់ទឹក ឬស្តុកទឹកដែលមានកម្ពស់ទាបជាង ឬលើសពី ១៥ (ដប់ប្រាំ) ម៉ែត្រ ឬមានចំណុះតិចជាង ឬលើសពី ៥០ (ហាសិប) ម៉ែត្រគូប

សំណង់មិនមែនជាអាគារដទៃទៀតដែលមានកម្ពស់ទាបជាង ឬលើសពី ៣០ (សាមសិប) ម៉ែត្រ។

[15] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, អនក្រ.បក.៣០/ធ្ន/២០២០, មាត្រា ៤ មាត្រា៥ និងមាត្រា៦។

# ជំពូកទី២

# ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃសំណង់ជាប់នឹងដី

នៅព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណី ត្រូវបានយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ ដែលបានកំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។

ចំពោះសំណង់ជាប់នឹងដីវិញ ការទទួលខុសត្រូវដោយយោងទៅតាមក្រមរដ្ឋប្បវេណីជាគោលគឺ ច្បាប់បានបញ្ញត្តិដោយពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល។ ជាក់ស្តែងផ្អែកលើក្រមរដ្ឋប្បវេណី មាត្រា ៧៥៣ ក្នុងករណីដែលការសាងសង់សំណង់ជាប់នឹងដី ឬការគ្រប់គ្រងសំណង់នោះ មានវិការៈហើយបានបណ្តាលឲ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីក្នុងការសាងសង់នោះ។ បន្ថែមពីបញ្ញត្តិដែលបានចែងអំពីការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដី ដោយកាលណាសំណង់ទាំងឡាយជាប់នឹងដីដូចជា អាគារ លំនៅឋាន ឬរបង ជាដើមបានធ្វើឱ្យខូចខាតទៅដល់អ្នកដទៃនោះដូចបានចែងក្នុងមាត្រាខាងលើអ្នកពាក់ព័ន្ធដែលបំពានក្នុងអំពើអនីត្យានុកូលត្រូវប្រឈមមុខចំពោះមុខច្បាប់ដោយជនរងគ្រោះ ឬអ្នករងគ្រោះអាចទាមទារព្យសនកម្មពីជនបង្កបាន ទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់។ អំពើអនីត្យានុកូលសំណង់ជាប់នឹងដី គឺច្បាប់ចាត់ទុកជាអំពើបំពានមួយដោយខុសច្បាប់ នូវសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ដោយកំហុសចេតនា ឬដោយអចេតនា ហើយជនដែលបានប្រព្រឹត្តអំពើនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដោយសារអំពើនោះ។ ទោះយ៉ាងជនដែលបានប្រព្រឹត្តអំពើបំពានមិនមែនប្រឈមមុខចំពោះមុខច្បាប់ពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល ជាគោលដៅមួយដើម្បីឱ្យជនរងគ្រោះ ឬអ្នករងគ្រោះមានសិទ្ធិទាមទារសំណងព្យសនកម្មតែមួយផ្នែកទេ ពោលគឺប្រព័ន្ធច្បាប់នៅកម្ពុជា ក៏បានបង្កើតឡើងមិនមែនដើម្បីជាផលប្រយោជន៍របស់បុគ្គលណាមួយ ប៉ុន្តែដើម្បីការពារទៅដល់សាធារណៈជនទាំងសិទ្ធិនិងផលប្រយោជន៍របស់ពួកគេ ព្រមទាំងផ្តល់នូវភាពយុត្តិធម៌ ជូនទៅកាន់ជនរងគ្រោះ អ្នករងគ្រោះ ឬជនបង្កនិងជាវិធីសាស្ត្រមួយដើម្បីអប់រំដល់អ្នកប្រព្រឹត្តដោយរាងចាល ហើយកាត់បន្ថយទង្វើអសកម្មនានាក្នុងសង្គម។

ដើម្បីសម្រួលដល់ការស្វែងរកអ្នកដែលទទួលខុសត្រូវទាំងឡាយពាក់ព័ន្ធនឹងអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីខាងលើ ដូចនេះត្រូវបានបែងចែកចេញជា ការទទួលខុសត្រូវអំពើអនីត្យានុកូលលើសំណង់ជាប់នឹដីក្នុងពេល និងក្រោយពេលសាងសង់ ។

## ២.១. ការទទួលខុសត្រូវអំពើអនីត្យានុកូលលើសំណង់ជាប់នឹងដីក្នុងពេលសាងសង់

ក្នុងការសាងសង់សំណង់ទាំងឡាយត្រូវបានកំណត់ជា រយៈពេលនៃការសាងសង់សំណង់ ឬរយៈពេលណាមួយដែលសំណង់ត្រូវបានសាងសង់បញ្ចប់ហើយ គឺផ្អែកទៅលើការយល់ស្របគ្នារវាងភាគីដែលបានកំណត់នៅក្នុងកិច្ចសន្យាសាងសង់នានា ឬកិច្ចសន្យាម៉ៅការ។ នៅក្នុងពេលសាងសង់ គឺជារយៈពេលមួយដែលចាត់ទុកថាសំណង់កំពុងតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីណាមួយនៅឡើយ ពោលគឺមានលក្ខណៈខុសគ្នាពីពេលសាងសង់រួច ដោយក្នុងការសាងសង់សំណង់ស្ថិតនៅក្រោមការគ្រប់គ្រងពីអ្នកម៉ៅការ ឬក្រុមហ៊ុនដែលទទួលបានសិទ្ធិក្នុងការសាងសង់។ ក្នុងល័ក្ខខ័ណ្ឌបែបនេះបើពិនិត្យមកលើ កម្មសិទ្ធិករ ឬ ម្ចាស់សំណង់វិញមិនទាន់បានគ្រប់គ្រងសំណង់របស់ខ្លួននៅឡើយទេ។

ក្នុងការសិក្សាលើការទទួលខុសត្រូវឱ្យកាន់តែលម្អិតទាមទារឲ្យមានការបែងចែកនូវភាគីទាំងឡាយដែលបានពាក់ព័ន្ធនឹងអំពើអនីត្យានុកូលគឺ ភាគីដែលទទួលរងព្យសនកម្ម និងភាគីដែលទទួលខុសត្រូវលើព្យសនកម្ម។ ភាគីដែលទទួលរងព្យសនកម្ម ចាត់ទុកថាជនរងគ្រោះជាជនទទួលរងការការខូចខាត (រាងកាយ ឬផ្នែកសម្ភារៈទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃផ្សេងៗ)បង្កដោយអំពើអនីត្យានុកូល។ រីឯភាគីដែលទទួលខុសត្រូវលើព្យសនកម្មជា ជនដែលបង្កអំពើអនីត្យានុកូលលើជនរងគ្រោះ។

### ២.១.១. ភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្ម

ទោះបីជាភាគីដែលទទួលខុសត្រូវលើព្យសនកម្មគឺជាជនដែលបង្កអំពើអនីត្យានុកូលមកលើជនរងគ្រោះក្តី ហើយក៏មានកាតព្វកិច្ចដើម្បីជួសជុលនូវការខូចខាតមកជនរងគ្រោះផ្អែកតាមច្បាប់ចំពោះអំពើបានប្រព្រឹត្ត។ ក្នុងពេលសាងសង់នេះភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្មត្រូវបានបែងចែកចេញជា រូបវន្តបុគ្គល(២.១.១.១) និងនីតិបុគ្គល (២.១.១.២) ។

#### ២.១.១.១ រូបវ័ន្តបុគ្គល

យោងតាមសន្ធានុក្រម រូបវន្តបុគ្គល មានន័យថា មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[16]។ រូបវន្តបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[17]។ ដូចនេះរូបវន្តគ្រប់រូបដែលបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ ដោយ កំហុសចេតនា កំហុសអចេតនា ឬបណ្តាលមកពីការធ្វេសប្រហែសមិនយកចិត្តទុកដាក់ រូបវន្តបុគ្គលនោះត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត។ ក្នុងពេលសាងសង់សំណង់ រូបវន្តបុគ្គលដែលអាចត្រូវទទួលខុសត្រូវមានដូចជា អ្នកម៉ៅការសំណង់ និងកូនជាង ឬកម្មករសំណង់។

---

[16]សន្ធានុក្រមនៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦ ។

### ក.អ្នកម៉ៅការសំណង់

លក្ខណៈជាទូទៅនៅតាមការសាងសង់សំណង់ខ្លះ កម្មសិទ្ធិករ ឬហៅជាសាមញ្ញ ម្ចាស់ផ្ទះ បានផ្តល់នូវសិទ្ធិទៅអោយអ្នកម៉ៅការសំណង់ ជំនួសដោយការសាងសង់ចាត់ចែងផ្ទាល់ ឬផ្នែកណាមួយនៃសំណង់របស់ខ្លួនទៅតាម រយៈការព្រមព្រៀងរវាងភាគីម្ចាស់ផ្ទះ និងអ្នកម៉ៅការសំណង់ អាចជាកិច្ចសន្យាម៉ៅការ ឬ កិច្ចសន្យាសាងសង់ជាលាយលក្ខណ៍អក្សរ។ យ៉ាងណាមិញទម្រង់ជាកិច្ចសន្យាទៅលើការសាងសង់សំណង់ករណីខ្លះអាចជាកិច្ចសន្យាផ្ទាល់មាត់ទៅលើការសាងសង់សំណង់ពីភាគី អ្នកម៉ៅការ និងម្ចាស់សំណង់។ប៉ុន្តែស្ថិតនៅក្នុងករណីជាកិច្ចសន្យាផ្ទាល់មាត់នេះក៏អាចជួបនូវហានិភ័យតាមរយៈការលើកយកភស្តុតាងមកបង្ហាញនៅពេលមានវិវាទកើតឡើងដែលវាជាផលវិបាកមួយ ផ្អែកលើការទុកចិត្តគ្នាទៅវិញទៅមករបស់គូភាគី តាមកិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់នេះ។

ការទាមទារឱ្យអ្នកម៉ៅការ ជាអ្នកទទួលខុសត្រូវលើព្យាសនកម្មចំពោះម្ចាស់ការ ត្រូវបានផ្អែកទៅលើកិច្ចសន្យាម៉ៅការ និង ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលចំពោះការទទួលខុសត្រូវរបស់និយោជក។ យោងតាមក្រមរដ្ឋប្បវេណី កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងមានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតមានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ[18]។ តាមរយៈកិច្ចសន្យាម៉ៅការនេះ ក៏ជាកិច្ចសន្យាមួយដែលកើតឡើងអំពីដោះដូរគ្នាទៅវិញទៅមកដោយយកតម្លៃការថ្នូរ នឹងការសាងសង់ដែលគូភាគីផ្តល់ឲ្យគ្នាទៅវិញទៅមក។ ព្រមទាំងអ្នកម៉ៅការសំណង់ មានករណីយកិច្ចដើម្បីសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់ការ[19] ។ ដោយហេតុថានៅក្នុងពេលសាងសង់ជាពេលវេលាមួយដែលសិទ្ធិក្នុងការសាងសង់ និងការគ្រប់គ្រងបានធ្លាក់ទៅដល់អ្នកម៉ៅការទទួលបន្ទុកពីម្ចាស់ការហើយនោះ នៅរាល់ករណីដែលបង្កហេតុដោយសំណង់តាមរយៈប្រការណាមួយនោះ ឬបង្កឱ្យមានអំពើអនីត្យានុកូលបង្កឡើងដោយសំណង់ទៅលើជនរងគ្រោះ អ្នកម៉ៅការសាងសង់ គឺជាជនដែលទទួលខុសត្រូវលើព្យាសនកម្ម។ លើសពីនេះទៅទៀតផ្អែកលើ ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលចំពោះការទទួលខុសត្រូវរបស់និយោជក ឃើញថានៅតាមការដ្ឋានតែងតែមាននិយោជក និងនិយោជិក។ ដោយចាត់ទុកថា អ្នកម៉ៅការ ជានិយោជក និងកូនជាងស្ថិតក្រោមឱវាទរបស់អ្នកម៉ៅការជានិយោជិក។ ដូចនេះអ្នកម៉ៅការសំណង់ដែលប្រើកូនជាងឱ្យធ្វើកិច្ចការណាមួយដើម្បីបម្រើដល់ផលប្រយោជន៍របស់ខ្លួនត្រូវទទួលត្រូវរាល់អំពើរបស់ខ្លួនបានបញ្ជាបុគ្គលជាកូនជាងនោះ។ នៅពេលដែលការងារលើសំណង់ជាប់នឹងដីរបស់អ្នកម៉ៅការសំណង់មានវិការៈ ឬ បណ្តាលឱ្យមានព្យសនកម្មបង្កឡើងទៅលើសំណង់ទ្រព្យសម្បត្តិនានា ឬព្យសនកម្មលើរូបរាងកាយដល់ជនរងគ្រោះដោយចេញពីកំហុសរបស់អ្នកម៉ៅការផ្ទាល់ ឬ ការ

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦៥២ ។

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦៥៤, កថាខណ្ឌទី១ ។

គ្រប់គ្រងកូនជាង និងការប្រើកូនជាងតាមការបញ្ជានៅក្រោមឱវាទរបស់ខ្លួននោះ អ្នកម៉ៅការជាបុគ្គលទទួលខុសត្រូវលើព្យសនកម្ម។ ប្រសិនជាការប្រព្រឹត្តសកម្មភាពផ្សេងៗ ដែលមិនមែនចេញពីអ្នកម៉ៅការសំណង់ជាអ្នកគ្រប់គ្រង បង្គាប់បញ្ជាទេ នោះការទទួលខុសត្រូវមិនធ្លាក់ទៅលើអ្នកម៉ៅការនោះទេ។

**ខ. កូនជាង ឬកម្មករសំណង់**

កូនជាង ឬកម្មករសំណង់ គឺជាជនស្ថិតក្រោមការគ្រប់គ្រង បង្គាប់បញ្ជាក្រោមឱវាទរបស់អ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសំណង់ណាមួយ ដោយមានតួនាទីជាជនបម្រើការងារឱ្យនិយោជក។ ក្នុងសកម្មភាពណាមួយដែលកើតឡើងតាម រយៈអំពើរបស់កូនជាង ឬកម្មករសំណង់ផ្ទាល់ ហើយមិនមែនចេញពីអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសំណង់ ជាអ្នកគ្រប់គ្រង បង្គាប់បញ្ជាទេនោះ ការទទួលបានបង្កឱ្យមានព្យសនកម្មជាបន្ទុករបស់កូនជាង ឬកម្មករសំណង់ដោយយោងតាមល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល។

**២.១.១.២ នីតិបុគ្គល**

យោងតាមសន្ធានុក្រម នីតិបុគ្គល សំដៅដល់ក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[20]។ នីតិបុគ្គលក៏មានការទទួលខុសត្រូវដូចទៅនឹងរូបវន្តបុគ្គលផងដែរ ដោយនៅក្នុងការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី ចំពោះនីតិបុគ្គលចែកចេញជាពីរ គឺ នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។

**ក. នីតិបុគ្គលឯកជន**

នីតិបុគ្គលឯកជន គឺជាបណ្តុំក្រុមមនុស្សមានចាប់ពី២នាក់ឡើងទៅ បង្កើតឡើងក្នុងគោលបំណងបម្រើដល់ផលប្រយោជន៍ឯកជន ដូចជា ក្រុមហ៊ុន សមាគមន៍ សហជីព ជាដើម។ ហើយសម្រាប់នីតិបុគ្គលឯកជនដែលទាក់ទងនឹងការទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ជាប់នឹងដីនេះ គឺនឹងត្រូវបានលើកឡើងចំពោះក្រុមហ៊ុនសាងសង់តែប៉ុណ្ណោះដោយមិនបានលើកយកមកបង្ហាញពីក្រុមហ៊ុនធានារ៉ាប់រង ឬគ្រឹះស្ថានធានារ៉ាប់រងក្នុងការទទួលខុសត្រូវនៅពេលសាងសង់នោះទេ ព្រោះដែនកំណត់នៃការស្រាវជ្រាវផ្តោតទៅលើភាគីបង្កព្យសនកម្មដោយផ្ទាល់។

ក្រុមហ៊ុនសាងសង់ គឺជាក្រុមមនុស្សមួយដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងអ្នកម៉ៅការសាងសង់ដែរ ត្រង់មានកាតព្វកិច្ចសាងសង់សំណង់ជាថ្នូរនឹងការដោះដូររបស់ភាគីម្ចាស់សំណង់។ប៉ុន្តែសង្កេតឃើញថានៅពេលមានគម្រោងសាងសង់ធំៗមិនថាតែម្ចាស់ផ្ទះល្វែង អាគារខុនដូ អាផាតមិន ជាដើមតែងតែមានទំនុកចិត្តស្វែងរកក្រុមហ៊ុនសាងសង់ក្នុងការកសាងគម្រោងរបស់ខ្លួន ព្រោះក្រុមហ៊ុនសាងសង់ មានមូលដ្ឋានទីស្នាក់ការច្បាស់លាស់ជាងបុគ្គលជាអ្នកម៉ៅការសាងសង់ ឬអាចពាក់ព័ន្ធនឹងលក្ខណៈបច្ចេកទេសនៃការសាងសង់ប្រសើរ

[20] សន្ធានុក្រមនៃក្រុមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

ផងដែរ។ ស្ទើរតែទាំងអស់នៃការសាងសង់ ក្រុមហ៊ុនសាងសង់ និងម្ចាស់សំណង់ បានចុះកិច្ចសន្យាព្រមព្រៀងគ្នា ដើម្បីសាងសង់សំណង់ដោយកំណត់ពីកាតព្វកិច្ចរបស់គូភាគីនីមួយៗត្រូវអនុវត្ត។ ហើយកាតព្វកិច្ចរបស់ក្រុមហ៊ុន សាងសង់ដែលជានីតិបុគ្គលឯកជនត្រូវសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់សំណង់។

ដូចនេះក្នុងករណីដែលក្រុមហ៊ុនសាងសង់បំពេញការងារមានព្យាសនកម្មណាមួយកើតឡើងនោះ ដោយសារតែលក្ខណៈបច្ចេកទេស ការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ការគ្រប់គ្រងសំណង់នៅមានកម្រិត ឬ បណ្តាលមកពីបុគ្គលិកធ្វើការតាមបង្គាប់បញ្ជាក្រុមហ៊ុនសាងសង់ ផ្អែកលើកិច្ចសន្យាសាងសង់ ឬកិច្ចព្រមព្រៀង នាំឱ្យ ក្រុមហ៊ុនសាងសង់ គឺជានីតិបុគ្គលឯកជនដែលទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់ ជាប់នឹងដី។

### ខ. នីតិបុគ្គលសាធារណៈ

នីតិបុគ្គលសាធារណៈ គឺជានីតិបុគ្គលដែលមានគោលដៅបម្រើដល់ផលប្រយោជន៍សាធារណៈទូទៅ ដូចជា រដ្ឋ និងបណ្តាគ្រឹះស្ថានសាធារណៈដទៃទៀត។ នីតិបុគ្គលសាធារណៈអាចជាក្រុមហ៊ុនសាងសង់របស់រដ្ឋ ដែលស្ថិតក្រោមសកម្មភាពក្នុងការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមាន អាគារ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យជាដើម។ ការអនុវត្តកាតព្វកិច្ចនៅក្នុងការទទួលខុសត្រូវ គឺស្ថាប័នសាធារណៈរបស់រដ្ឋឬ រដ្ឋផ្ទាល់ ត្រូវទទួលខុសត្រូវលើព្យសនកម្មដែលបង្កឡើងដោយមន្ត្រីរាជការពេលបំពេញការងារ។ ប៉ុន្តែក្នុងករណីនេះក៏ស្រដៀង គ្នាទៅនឹងការទទួលខុសត្រូវព្យសនកម្មរបស់កូនជាងផងដែរ ប្រសិនជាការបង្កព្យសនកម្មនោះកើតចេញពីកំហុស របស់មន្ត្រីរាជការផ្ទាល់នោះ មន្ត្រីរាជការនោះត្រូវទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី។ លើសពីនេះទៅទៀតករណីកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការក្នុងការជៀសវាងនូវលទ្ធផលមាន ស្ថានភាពធ្ងន់ធ្ងរពេក រដ្ឋក៏អាចទាមទារសំណងការខូចខាតពីមន្ត្រីរាជការបានដូចជនរងគ្រោះ ឬអ្នករងគ្រោះដែរ ផ្អែកតាមអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ[21]។

## ២.២. ការទទួលខុសត្រូវអំពើអនីត្យានុកូលលើសំណង់ជាប់នឹងដីក្រោយពេលសាងសង់

នៅពេលក្រោយការសាងសង់បានបញ្ចប់ គឺជាពេលវេលាមួយដែលសំណង់ជាប់នឹងដីបានសាងសង់ រួចរាល់ទៅតាមការព្រមព្រៀងគ្នារវាងនីតិបុគ្គល ឬបុគ្គលដែលមានកាតព្វកិច្ចក្នុងការសាងសង់ និងភាគីខាង ម្ចាស់សំណង់។ ក្នុងករណីដែលបានសាងសាងសំណង់រួចភាគីដែលទទួលខុសត្រូវលើព្យសនកម្មនឹងត្រូវបាន បែកចែកទៅតាមចំណុចនីមួយៗ។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៩ ។

### ២.២.១. ភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្ម

នៅក្រោយពេលសាងសង់បានបញ្ចប់ប្រសិនបើនីតិបុគ្គល ឬបុគ្គលដែលមានកាតព្វកិច្ចសាងសង់មិនទាន់បានប្រគល់ឱ្យទៅខាងម្ចាស់សំណង់នោះទេ ការទទួលខុសត្រូវចំពោះព្យសនកម្មនៅតែមានលក្ខណៈដូចគ្នាទៅនឹងការទទួលខុសត្រូវអំពើអនីត្យានុកូលក្នុងពេលកំពុងសាងសង់ដែរ ព្រោះការគ្រប់គ្រង ក៏ដូចជាកាតព្វកិច្ចរបស់ភាគីសាងសង់នៅមាននៅឡើយ ហើយកម្មសិទ្ធិករពុំទាន់បានគ្រប់គ្រងសំណង់ជាកម្មសិទ្ធិរបស់គេទេ។

ប៉ុន្តែនៅពេលដែលបុគ្គល ឬនីតិបុគ្គលមានកាតព្វកិច្ចសាងសង់បានប្រគល់សំណង់រួចរាល់ទៅឱ្យកម្មសិទ្ធិករជាអ្នកគ្រប់គ្រងវិញភាគីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើព្យសនកម្មមានដូចជា អ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់(២.២.១.១) កូនជាង ឬកម្មករសំណង់(២.២.១.២) កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ(២.២.១.៣) អ្នកគ្រប់គ្រងសំណង់(២.២.១.៤) ។

#### ២.២.១.១ អ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់

ដូចបានបកស្រាយនៅត្រង់ការទទួលខុសត្រូវរបស់អ្នកម៉ៅការសាងសង់ និងក្រុមហ៊ុនសាងសង់ក្នុងពេលសាងសង់ផងដែរ ដោយបុគ្គល និងនីតិបុគ្គលទាំងពីរមានករណីយកិច្ចសាងសង់សម្រេចនូវការងារដោយគ្មានវិការៈចំពោះកម្មសិទ្ធិករ ក្នុងន័យនេះនៅពេលដែលសំណង់បានប្រគល់ទៅឱ្យកម្មសិទ្ធិកររួចរាល់ តែសំណង់ដែលបានប្រគល់នោះបានបង្កឱ្យមានការខូចខាតដោយសារតែ បច្ចេកទេសនៃការសាងសង់មិនត្រឹមត្រូវ ឬការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន អ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់មានកាតព្វកិច្ចទទួលខុសត្រូវលើព្យសនកម្មដែលកើតមាន។ ហើយកម្មសិទ្ធិករអាចការទាមទារសំណងការខូចខាតពីអ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់ចំពោះសំណងដែលខ្លួនបានសងទៅកាន់ជនរងគ្រោះផ្អែកលើកិច្ចសន្យាម៉ៅការ ឬកិច្ចសន្យាសាងសង់តែប៉ុណ្ណោះ។ ប៉ុន្តែការទាមទារ កម្មសិទ្ធិករមិនអាចទាមទារឲ្យអ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់ដែលបានស្លាបនាឲ្យទទួលខុសត្រូវលើអំពើអនីត្យានុកូលទេ ហេតុថាកម្មសិទ្ធិករជាអ្នកគ្រប់គ្រងសំណង់នៅពេលប្រគល់សំណង់រួចរាល់ ហើយករណីរកឃើញថាកម្មសិទ្ធិករបានបង្កឱ្យមានព្យសនកម្ម តាមរយៈការធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នជាដើម។

#### ២.២.១.២ កូនជាង ឬកម្មករសំណង់

កូនជាង ឬកម្មករសំណង់ គឺជាជនស្ថិតក្រោមការគ្រប់គ្រង បង្គាប់បញ្ជាក្រោមឱវាទរបស់អ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសំណង់ណាមួយ ដោយមានតួនាទីជាជនបម្រើការងារឱ្យនិយោជក។ ការលើកឡើងនេះមានលក្ខណៈស្រដៀងគ្នានៅត្រង់ការទទួលខុសត្រូវរបស់កូនជាង ឬកម្មករសំណង់នាពេលសាងសង់សំណង់ដែរ ដោយក្នុងសកម្មភាពណាមួយដែលកើតឡើងតាមរយៈអំពើរបស់កូនជាង ឬកម្មករសំណង់ផ្ទាល់ ហើយមិនមែនចេញពីអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសំណង់ ជាអ្នកគ្រប់គ្រង បង្គាប់បញ្ជាទេនោះ ដូចករណីត្រូវបានរកឃើញថា កូនជាង ឬ

កម្មករសំណង់ព្យាយាមលាក់បាំងភាពជាក់ស្តែងនៃលក្ខណៈបច្ចេកទេស ហើយស្រាប់តែក្រោយពេលសំណង់បានប្រគល់រួចរាល់មួយរយៈពេលខ្លី សំណង់នោះមានវិការៈនៃបច្ចេកទេសបង្កអោយមានការខូចខាតដល់អ្នកដទៃ ដោយអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសំណង់ត្រូវបានកូនជាងបំភាន់ព័ត៌មាន ដូចនេះ ការទទួលបានបង្កឱ្យមានព្យសនកម្មជាបន្ទុករបស់កូនជាងយោងតាមល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល។ ប៉ុន្តែករណីបង្កដោយកូនជាង ឬកម្មករសំណង់ពេលប្រគល់សំណង់រួចរាល់នេះចាត់ទុកជាករណីកម្រមួយ។ ឧទាហរណ៍៖ ការផ្លាស់ប្តូរទំហំដែកនៃបច្ចេកទេសសាងសង់ពីសំណាក់កូនជាង ឬកម្មករសំណង់ដោយបំភាន់ព័ត៌មានទៅថៅកែ ក្នុងគោលបំណងយកដែកក្នុងការដ្ឋាននោះទៅលក់ឲ្យអ្នកដទៃដើម្បីប្តូរជាប្រាក់។

### ២.២.១.៣ កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ

#### ក. កម្មសិទ្ធិករ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតបានកម្រិត[22]។

រីឯកម្មសិទ្ធិករ គឺជាម្ចាស់នៃសិទ្ធិដែលជាបុគ្គលឯកជន អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន។ ហើយម្ចាស់នៃសិទ្ធិ សំដៅដល់បុគ្គល ឬនីតិបុគ្គលដែលសិទ្ធិក្នុងការប្រើប្រាស់អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនក្នុងទំហំណាមួយដែលច្បាប់ផ្តល់ទៅឱ្យ។ នៅក្នុងការលើកយកមកបង្ហាញនេះគឺជា កម្មសិទ្ធិដីដោយត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដី នៅក្នុងទំហំដែលច្បាប់បានកំណត់ និង បទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ ព្រមទាំងកម្មសិទ្ធិករនៃដី មិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងបំពានដល់អ្នកដទៃនោះទេបានឡើយ[23]។ ដូចនេះក្នុងករណីដែលមានអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីកើតឡើង កម្មសិទ្ធិករ គឺជាអ្នកដែលទទួលខុសត្រូវលើព្យសនកម្មទាំងស្រុង ប្រសិនបើរកឃើញថាសិទ្ធិលើកម្មសិទ្ធិ និងការគ្រប់គ្រងសំណង់ជាប់នឹងដីនោះស្ថិតក្នុងបន្ទុករបស់កម្មសិទ្ធិករដោយខ្លួនឯង។ យ៉ាងណាមិញ កម្មសិទ្ធិករមិនមែនជាអ្នកទទួលខុសត្រូវទាំងស្រុងទេ ក្នុងករណីដែលកម្មសិទ្ធិករបានជួល ឬប្រគល់ការគ្រប់គ្រងសំណង់ជាប់នឹងដីរបស់ខ្លួន ទៅឱ្យភាគីណាមួយ នោះភាគីជាកម្មសិទ្ធិករ និងអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ[24]។ ឧទាហរណ៍ៈ ក្នុងករណីរបងផ្ទះជួលបានរលំ ហើយបានធ្វើឱ្យអ្នកដើររងរបួសនោះ ម្ចាស់ផ្ទះ(ភតិបតី) និងអ្នកជួល(ភតិកៈ)ត្រូវ

[22] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, មាត្រា ១៣ ។
[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៩ ។
[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៣ ។

ទទួលបន្ទុកនូវសំណងនៃការខូចខាតដោយសាមគ្គីភាព។ កម្មសិទ្ធិករពុំអាចរួចផុតពីការទទួលខុសត្រូវបានទេ តែអាចទាមទារពីអ្នកគ្រប់គ្រងបានបើសិនរកឃើញថាជាកំហុសរបស់អ្នកគ្រប់គ្រង។

**ខ. សហកម្មសិទ្ធិករ**

សហកម្មសិទ្ធិ សំដៅទៅលើភាពជាកម្មសិទ្ធិរួមគ្នាមួយ រវាងបុគ្គលច្រើននាក់ក្នុងការកាន់កាប់សិទ្ធិលើអចលនវត្ថុទៅតាមចំណែករបស់បុគ្គលម្នាក់ៗ។ សហកម្មសិទ្ធិករ មានន័យថាជានីតិបុគ្គលមានសិទ្ធិលើសហកម្មសិទ្ធិ ក្នុងការចាត់ចែង ប្រើប្រាស់ អាស្រ័យផលទៅតាមចំណែករបស់បុគ្គលឯកជនរៀងៗខ្លួន និងបុគ្គលទាំងនោះមានសិទ្ធិលើកម្មសិទ្ធិអវិភាគ ។ កម្មសិទ្ធិអវិភាគ គឺជាស្ថានភាពដែលបុគ្គលច្រើននាក់ មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ[25]។ ចំពោះសហកម្មសិទ្ធិករត្រូវមានភារកិច្ចទៅលើការថែទាំ ជួសជុលដែលជាបន្ទុករបស់សហកម្មសិទ្ធិករគ្រប់ៗរូបដោយមានការបែងចែកនូវចំណែកនៃការចូលរួមនោះដោយស្មើភាពគ្នាទៅលើបុគ្គលរៀងៗខ្លួន[26]។ ដូចនេះក្នុងករណីដែលមានការបង្កព្យសនកម្មណាមួយស្ថិតក្នុងបន្ទុករួមគ្នារបស់សហកម្មសិទ្ធិករ នោះសហកម្មសិទ្ធិករត្រូវទទួលខុសត្រូវទៅលើទំហំនៃការខូចខាតនោះរួមគ្នាដោយសាមគ្គី ដែលមានការបែងចែកទៅតាមចំណែករៀងៗខ្លួនក្នុងការសងសំណងដោយទទួលខុសត្រូវទៅលើជនរងគ្រោះដែលទទួលបាននូវព្យសនកម្មនោះ។ ឧទាហរណ៍៖ ករណីអគ្គីភ័យបង្កចេញពីសំណង់ជាប់នឹងដីរបស់សហកម្មសិទ្ធិករនាំឱ្យមានការខូចខាតដល់ជនរងគ្រោះ នោះសហកម្មសិទ្ធិករត្រូវទទួលខុសត្រូវលើទំហំដែលបានបង្កអំពើអនីត្យានុកូលដោយសាមគ្គី។

**២.២.១.៤. អ្នកគ្រប់គ្រងសំណង់**

អ្នកគ្រប់គ្រងសំណង់ សំដៅដល់អ្នកដែលកាន់កាប់ ថែរក្សា អាចជាបុគ្គលដែលមើលថែរក្សាជំនួសកម្មសិទ្ធិករក្នុងរយៈពេលខ្លី ឬវែង ឬ ភតិកៈដែលជាបុគ្គលទទួលបានសិទ្ធិប្រើប្រាស់ អាស្រ័យផលពីសំណង់របស់ភតិបតី។ នៅត្រង់ចំណុចបុគ្គលដែលមើលថែរក្សាជំនួសកម្មសិទ្ធិករស្ថិតក្នុងរយៈពេលខ្លី ឬវែង សំដៅដល់បុគ្គលទាំងឡាយអាចជាសាច់ញ្ញាតិ បងប្អូន ឬបុគ្គលដែលកម្មសិទ្ធិករទុកចិត្តបានជួយមើលការខុសត្រូវជំនួសកម្មសិទ្ធិករអំឡុងពេលដែលកម្មសិទ្ធិករពុំបានគ្រប់គ្រងសំណង់របស់ខ្លួនដោយផ្ទាល់។ ករណីប្រសិនបើបុគ្គលដែលមើលថែរក្សាជំនួសកម្មសិទ្ធិករនោះបានបង្កឱ្យមានការខូចខាតដោយជាកំហុសទាំងស្រុងរបស់ខ្លួន បុគ្គលនេះត្រូវទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់។ ប៉ុន្តែបើរកឃើញថាមិនមានជាកំហុសទាំងស្រុងរបស់

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០២ ។

[26] ស្រី វណ្ណធី, នីតិរដ្ឋប្បវេណី, ២០១៦, ៣៧-៤៤ ។

បុគ្គលដែលមើលថែរក្សាជំនួសកម្មសិទ្ធិករក្នុងរយៈពេលខ្លី ឬវែងទេនោះ ទាំងកម្មសិទ្ធិករ និងបុគ្គលមើលថែជំនួស ត្រូវទទួលខុសត្រូវដោយសាមគ្គី និងការទទួលខុសត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ[27]។

លើសពីនេះទៅទៀត អ្នកគ្រប់គ្រងសំណង់ជាភតិកៈការទទួលខុសត្រូវក៏ត្រូវបានអនុវត្តដូចទៅនឹង បុគ្គលដែលមើលថែរក្សាជំនួសកម្មសិទ្ធិករក្នុងរយៈពេលខ្លី ឬវែងដែរ។ ប៉ុន្តែករណីអ្នកគ្រប់គ្រងសំណង់បាន អះអាង ឬបញ្ជាក់ភស្តុតាង អំពីការគ្រប់គ្រងថាខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងអាចរួចផុតពីការ ទទួលខុសត្រូវបាន[28]។

## ២.៣. លក្ខខណ្ឌនៃការទទួលខុសត្រូវលើករណីនីមួយៗនៃសំណង់ជាប់នឹងដី

ការទទួលខុសត្រូវលើការខូចខាតដែលបង្កដោយសំណង់ជាប់នឹងដី អាចប្រព្រឹត្តទៅបានអាស្រ័យលើ កម្មវត្ថុនៃការខូចខាតនោះបានបង្កដោយសំណង់ពិតប្រាកដ ឬមូលហេតុដែលបង្ក កើតឡើងដោយសារតែផ្នែក ណាមួយនៃសំណង់នោះពិតមែន ដោយការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ឬមានវិការៈអ្វីមួយបានកើតឡើង។ ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវលើករណីនីមួយៗនៃសំណង់ចាប់នឹងដីមានដូចជា ករណីមានអគ្គីភ័យ ប្រើប្រាស់ ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់ ការបាក់បែក ខូចទ្រង់ទ្រាយ ឬរលុំសំណង់ វិការៈនៃគុណភាពសំណង់ ឬ ការគ្រប់គ្រង និងការខូចខាតដោយសារករណីផ្សេងៗទៅដល់បុគ្គលដ៏ទៃ ។

### ២.៣.១ ករណីមានអគ្គីភ័យ

ករណីអគ្គីភ័យបង្កដោយសំណង់គឺជាករណីមួយដែលតែងតែកើតមានជារឿយៗនៅក្នុងសង្គម។ ហើយ ករណីអគ្គីភ័យនេះចំពោះសំណង់ជាប់នឹងដីគឺអាចបង្កឡើងដោយសារមូលហេតុផ្សេងៗដូចជាការធ្វេសប្រហែស ខ្ជីខ្ជាមិនប្រុងប្រយ័ត្ន កង្វះនៃការគ្រប់គ្រង ជាដើមដែលបង្កជាអគ្គីភ័យឱ្យមានការខូចខាតដល់ជនរងគ្រោះ និង ជនដែលបង្កត្រូវទទួលខុសត្រូវលើអំពើអនីត្យានុកូលរបស់ខ្លួនប្រព្រឹត្តដែលទាមទារឱ្យត្រូវស្វែងរក តើប្រភពអគ្គី ភ័យដែលបានកើតឡើងនោះចេញពីប្រភពណា? និងតើនរណាជាអ្នកទទួលខុសត្រូវក្នុងករណីខាងលើនេះ ព្រម ទាំងការជួសជុលព្យសនកម្មពីជនបង្កស្ថិតក្នុងទំហំណា?

ការទទួលខុសត្រូវនៅក្នុងករណីអគ្គីភ័យនេះតម្រូវឲ្យដើមហេតុដែលបង្កឲ្យមានការខូចខាតនោះ ដោយ កើតចេញពីផ្នែកណាមួយនៃសំណង់ ឬអាគារជាប់នឹងដីមានភស្តុតាងនៅក្នុងការលើកយកមកបញ្ជាក់ថាវាពិត ជាបានកើតឡើងដោយសារតែអគ្គីភ័យនៃសំណង់ ឬអាគារនោះជាប្រភពនៃភ្លើងដែលបង្កឱ្យរីករាលដាលទៅ ដល់អ្នកដទៃ ឬជាប្រភពនៃភ្លើងដែលបានឆាបឆេះរាលដាលទៅដល់ទីលំនៅស្ថានរបស់អ្នកជិតខាងដែលបាន បង្កឡើងដោយម្ចាស់សំណង់ ឬអ្នកគ្រប់គ្រងសំណង់អាគារនោះ ។ ហើយការជួសជុលព្យសនកម្មពីជនបង្កស្ថិត

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៣ កថាខណ្ឌទី២ ។

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៣ កថាខណ្ឌទី១ ។

ក្នុងទំហំជាក់ស្តែង[29]។ ដូចនេះភាគីដែលពាក់ព័ន្ធក្នុងការទទួលខុសលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីក្នុងករណីអគ្គីភ័យមានដូចជា អគ្គីភ័យបង្កដោយម្ចាស់កម្មសិទ្ធិករ(២.៣.១.១) និងអគ្គីភ័យបង្កដោយអ្នកមានសិទ្ធិគ្រប់គ្រងជំនួស(២.៣.១.២)។

### ២.៣.១.១ អគ្គីភ័យបង្កដោយម្ចាស់កម្មសិទ្ធិករ

ករណីដែលអគ្គីភ័យបានបង្កឡើងដោយសំណង់ជាប់នឹងដី ស្ថិតក្នុងស្ថានភាពដែលម្ចាស់កម្មសិទ្ធិករថែរក្សា ម្ចាស់កម្មសិទ្ធិករត្រូវទទួលខុសត្រូវទៅលើការខូចខាតដែលខ្លួនបានបង្កអោយមានទៅដល់ជនរងគ្រោះ ប្រសិនបើអគ្គីភ័យនោះមានធ្វើអោយមានការខូចខាត ប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬអ្នកដទៃដោយសារតែការធ្វេសប្រហែស មិនប្រុងប្រយ័ត្នចេញពីកំហុសចេតនា ឬអចេតនារបស់ម្ចាស់កម្មសិទ្ធិ។ ដូចនេះហើយម្ចាស់កម្មសិទ្ធិករមិនអាចគេចពីការមិនទទួលខុសត្រូវឡើយករណីខ្លួនបានបង្ក និងត្រូវផ្តល់ជាសំណងលើព្យសនកម្មយ៉ាងពេញទីទៅដល់ជនរងគ្រោះផ្អែកលើទំហំដែលបានខូចខាត[30]។

### ២.៣.១.២ អគ្គីភ័យបង្កដោយអ្នកមានសិទ្ធិគ្រប់គ្រងជំនួស

ដូចបានបញ្ជាក់ពីខាងលើដែរទាក់ទងនឹងករណីមានអគ្គីភ័យ ដែលតម្រូវឲ្យមានការទទួលខុសត្រូវ គឺសំណង់ ឬអាគារនោះជាប្រភពនៃអគ្គីភ័យដោយចេញពីការមិនប្រុងប្រយ័ត្ន ឬខ្វះការថែទាំ យកចិត្តទុកដាក់ពីសំណាក់ភាគីដែលបង្ក។ ចំពោះអគ្គីភ័យបង្កដោយអ្នកមានសិទ្ធិគ្រប់គ្រងជំនួស អាចជាអ្នកមើលថែបណ្តោះអាសន្ន ឬ ភតិកៈ ក៏ស្ថិតក្នុងការទទួលខុសត្រូវលើអំពើអនីត្យានុកូលដូចគ្នា ប៉ុន្តែក្នុងករណីអគ្គីភ័យនេះគឺបានកើតឡើងដោយសារអ្នកមានសិទ្ធិគ្រប់គ្រងជំនួសធ្វេសប្រហែស មិនប្រុងប្រយ័ត្នដោយខ្លួនឯងផ្ទាល់បង្កអោយប៉ះពាល់ដល់អ្នកដទៃនោះអ្នកមានសិទ្ធិគ្រប់គ្រងជំនួសត្រូវទទួលខុសត្រូវលើព្យសនកម្មដល់ជនរងគ្រោះផ្អែកលើល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល ។

### ២.៣.២ ប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់

ក្នុងករណីដែលបានប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់វិញ ជនដែលទទួលខុសត្រូវលើព្យសនកម្មត្រូវតែមានចំពោះជនរងគ្រោះ។ កាលដែលប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់នេះ ប្រសិនបើ បង្កអោយលក្ខណៈបច្ចេកទេសក្នុងការសាងសង់នោះមានជួបនូវវិការៈ ហើយបើកាលដែលសំណង់របស់ម្ចាស់កម្មសិទ្ធិករនោះបានបង្កនូវការខូចខាតដល់អ្នកដទៃដោយប្រការណាមួយនោះ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិករ ហេតុថានៅពេលដែលអាជ្ញាធរបានត្រួតពិនិត្យនិងវាយតម្លៃលើប្លង់ដែលកម្មសិទ្ធិករបានបញ្ជូនទៅឃើញថាសមស្រប និងគោរពតាមបទដ្ឋានបច្ចេកទេសទើបចេញលិខិត

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៦៣ ។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៦៣ ។

អនុញ្ញាតសាងសង់ឱ្យ។ ប៉ុន្តែនៅពេលសាងសង់ជាក់ស្តែងឃើញថាសំណង់របស់ម្ចាស់កម្មសិទ្ធិករសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់ ក្នុងន័យនេះមានន័យថា ម្ចាស់កម្មសិទ្ធិករបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ដោយទទួលយកការកើតឡើងនៃលទ្ធផលដែលប្រឈមក្នុងការសាងសង់សំណង់របស់ខ្លួន ហើយនៅតែជំនះសាងសង់ទៀត។ លើសពីនេះទៅទៀតចំពោះការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីនេះមិនពាក់ព័ន្ធនឹងអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់នោះទេ ព្រោះជាកំហុសចេតនារបស់ម្ចាស់កម្មសិទ្ធិករ ដោយខ្លួនបានដឹង និងយល់ព្រមលើប្លង់ដែលខុសនោះរួចជាស្រាច់។

ឧទាហរណ៍៖ លិខិតអនុញ្ញាតសាងសង់បានអនុញ្ញាតឱ្យម្ចាស់កម្មសិទ្ធិករសាងសង់អាគារនៅលើដីរបស់ខ្លួនត្រឹម១០ជាន់ប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងម្ចាស់កម្មសិទ្ធិករសាងសង់អាគារនោះរហូតដល់១២ជាន់។

ដូចនេះកាលដែលបានប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់ ម្ចាស់កម្មសិទ្ធិករត្រូវតែទទួលខុសត្រូវទៅលើការខូចខាតដែលបានបង្កទៅដល់ជនរងគ្រោះទាំងស្រុង ហើយជនរងគ្រោះក៏អាចទាមទារនូវសំណងព្យសនកម្មពីកម្មសិទ្ធិករវិញបានដែរផ្អែកលើការទទួលខុសត្រូវលើអំពើអនីត្យានុកូល[31]។

### ២.៣.៣ ការបាក់បែក ខូចទ្រង់ទ្រាយ ឬរលុំសំណង់

ការទទួលខុសត្រូវក្នុងករណីមានការបាក់បែក ខូចទ្រង់ទ្រាយ ឬរលុំសំណង់នេះ គឺតម្រូវឱ្យសំណង់ទាំងឡាយជាប់នឹងដីបានបង្កឱ្យមានព្យសនកម្មដោយសារតែអំពើនៃការខូចខាតរបស់ផ្នែកណាមួយរបស់សំណង់ ឬសំណង់ទាំងស្រុងផ្អែកទៅលើវិការៈនៃសំណង់ ឬការធ្វេសប្រហែសណាមួយនៃការសាងសង់សំណង់ ត្រូវមានភស្តុតាងជាក់ស្តែងនៅក្នុងការដាក់បន្ទុកទៅលើសំណង់នោះថាជាដើមហេតុដែលបង្កការខូចខាតដល់អ្នកដទៃពិតប្រាកដ។ ដូចនេះកម្មសិទ្ធិករត្រូវតែទទួលខុសត្រូវទៅលើការខូចខាតដែលបានបង្កទៅដល់ជនរងគ្រោះទាំងស្រុងដោយមិនអាចប្រកែកបាន ហើយជនរងគ្រោះក៏អាចទាមទារនូវសំណងព្យសនកម្មពីកម្មសិទ្ធិករវិញបានដែរ។

### ២.៣.៤. វិការៈនៃគុណភាពសំណង់ ឬការគ្រប់គ្រង

វិការៈនៃគុណភាពសំណង់ឬការគ្រប់គ្រង មានន័យថាការកើតឡើងនូវភាពមិនប្រក្រតីនៅត្រង់ចំណុចណាមួយនៃគុណភាពរបស់ការសាងសង់ ឬគ្រប់គ្រងដែលនាំឱ្យសំណង់ជាប់នឹងដីនោះមានការដួលរលំ ឬបាក់ស្រុត ករណីផ្សេងៗដែលកើតឡើងដោយសារតែការសាងសង់សំណង់របស់ស្ថាបត្យករ ឬសហគ្រិនសាងសង់នៃសំណង់ជាប់នឹងដីនោះមិនសមស្របទៅតាមបទដ្ឋានបច្ចេកទេសសាងសង់ ដូចទៅនឹងការប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់ដែរ ឬបញ្ហាបច្ចេកទេស ឬបញ្ហាគុណភាពដែលបង្កឲ្យមានការខូចខាតនេះកើតឡើង។ ប៉ុន្តែម្ចាស់កម្មសិទ្ធិករក៏នៅតែទទួលខុសត្រូវទៅលើការខូចខាតទៅកាន់ជនរងគ្រោះដែរ ហេតុថាជាកាតព្វកិច្ចនៃការទទួលខុសត្រូវរបស់ម្ចាស់កម្មសិទ្ធិករ។ ក្រៅពីការទទួលខុសត្រូវលើជនរងគ្រោះហើយ ម្ចាស់កម្មសិទ្ធិករក៏មាន

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤២ ចំណុច ក ។

សិទ្ធិក្នុងការទាមទារនូវសំណងការខូចខាតនោះពីស្ថាបត្យករ ឬសហគ្រិនសាងសង់នោះមកវិញបានដោយសារតែមានកំហុសខាងវិការៈនៃការសាងសង់ មិនមែនជាកំហុសដែលកើតចេញពីម្ចាស់កម្មសិទ្ធិករទេ។

### ២.៣.៥ ការខូចខាតដោយសារករណីផ្សេងៗទៅដល់បុគ្គលដទៃ

ករណីដែលបង្កអោយមានការខូចខាតដោយសារករណីផ្សេងៗទៅដល់បុគ្គលដទៃនេះ គឺជាល័ក្ខខ័ណ្ឌមួយដែលមូលហេតុនៃការខូចខាតកើតមានឡើងក្រៅពី ករណីមានអគ្គីភ័យ ការប្រើប្រាស់ប្លង់ខុសពីលិខិតអនុញ្ញាតសាងសង់ ការបាក់បែក ខូចទ្រង់ទ្រាយ ឬរលុំសំណង់ និងវិការៈនៃគុណភាពសំណង់ ឬការគ្រប់គ្រង។ ដែលតម្រូវឱ្យមានការសងនូវព្យសនកម្មដោយសារតែអំពើប្រព្រឹត្តរបស់ជនបង្កទៅលើសកម្មភាព ឬទង្វើណាមួយនោះបានបង្កឱ្យមានផលប៉ះពាល់ទៅដល់ជនរងគ្រោះមិនថាជាការខូចខាតទៅលើផ្នែករូបរាងកាយ ស្មារតី ឬទ្រព្យសម្បត្តិនោះទេ ក៏នៅតែជាបន្ទុករបស់ជនបង្កនៅក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដដែល។

## ២.៤. ល័ក្ខខ័ណ្ឌដែលរួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលជាប់នឹងដី

ទោះបីជាច្បាប់បានផ្ដល់នូវការការពារទៅឱ្យជនរងគ្រោះ និងអ្នករងគ្រោះពីអំពើអនីត្យានុកូលអាចមានសិទ្ធិទាមទារសំណងព្យសនកម្មបាន។ យ៉ាងណាមិញច្បាប់ក៏បានផ្ដល់ការការពារដូចគ្នាចំពោះជនបង្កដែលបានប្រព្រឹត្តនាំអោយមានការខូចខាតដល់អ្នកដទៃ ប៉ុន្តែក្នុងន័យនេះ ជនបង្កអាចរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនបានប៉ុន្តែច្បាប់មិនបានផ្ដល់សិទ្ធិឱ្យជនបង្កអាចទាមទារសំណងពីជនរងគ្រោះបានវិញទេ ព្រោះសំណង់ជាប់នឹងដីរបស់ជនបង្កបានបង្កើតឱ្យមានអំពើអនីត្យានុកូលលើជនរងគ្រោះ។ ហេតុនេះហើយល័ក្ខខ័ណ្ឌដែលរួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលជាប់នឹងដីមានដូចជា ការយល់ព្រមពីជនរងគ្រោះ ឬជាកំហុសទាំងស្រុងរបស់ជនរងគ្រោះ អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផល ការកំណត់ពេល និងអំឡុងពេលបង្កើត និងរលត់អានុភាពនៃកិច្ចសន្យាលើសំណង់ និង អសមត្ថភាពនៃការទទួលខុសត្រូវ។

### ២.៤.១ ការយល់ព្រមពីជនរងគ្រោះ ឬជាកំហុសទាំងស្រុងរបស់ជនរងគ្រោះ

នៅត្រង់ល័ក្ខខ័ណ្ឌនៃការយល់ព្រមពីជនរងគ្រោះនេះ បុគ្គលដែលបានប្រព្រឹត្តអំពើអនីត្យានុកូលអាចរួចផុតពីការការទទួលខុសត្រូវបាន ក្នុងករណីមានការយល់ព្រម ឬទទួលយកគ្រោះថ្នាក់ពីសំណាក់ជនរងគ្រោះ[32]។ ដោយករណីខាងលើនេះជនរងគ្រោះមានសិទ្ធិសម្រេចចិត្តដោយប្រការណាមួយ មិនធ្វើការទាមទារសំណងទៅលើជនដែលបានបង្ក ឬមិនចាំបាច់ឱ្យជនបង្កសងការខូចខាតដល់ខ្លួនវិញបានដែរ។

រីឯកំហុសទាំងស្រុងរបស់ជនរងគ្រោះវិញ បុគ្គលដែលបានបង្កឱ្យមានការខូចខាតដល់អ្នកដទៃអាចរួចផុតពីការទទួលខុសត្រូវបាន ប្រសិនបើការដែលបានខូចខាតនោះត្រូវបានរកឃើញថាជាកំហុសរបស់ជនរងគ្រោះផ្ទាល់ ក្នុងន័យនេះសំដៅដល់បុគ្គលដែលបង្កឱ្យមានអំពើអនីត្យានុកូលសំណង់ជាប់នឹងដីគឺមិនមានជាកំហុសក្នុង

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៦ ។

ការបង្កឲ្យមានអំពើអនីត្យានុកូលកើតឡើងលើសំណង់ជាប់នឹងដីណាមួយនោះឡើយ ដោយវាជាការបង្កឡើងដោយសារតែកំហុសរបស់ជនរងគ្រោះ។

### ២.៤.២ អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផល

អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផលចាត់ជា អំពើទាំងឡាយណាដែលមនុស្សមិនអាចទុកស្មាត់បាន ឬមិនចេញពីឆន្ទៈរបស់ជនបង្កដែលបានធ្វើឱ្យខូចខាត ប៉ះពាល់ដល់អ្នកដទៃ។ អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផល គឺជាករណីប្រធានសក្តិ។ ករណីប្រធានសក្តិ សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍ដែលកើតឡើង ដោយមិនដឹងជាមុន ដែលមិនអាចប៉ាន់ស្មានទុកជាមុនបាន និងមិនអាចជំនះបានដូចជាគ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុបកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ[33]។

ឧទាហរណ៍៖ ករណីដែលបានបណ្តាលឱ្យសំណង់ទទួលរងនូវការខូចខាតដោយស្ថិតនៅក្នុងពេលសាងសង់ដូចជា ការបាក់ ឬស្រុតផ្នែកណាមួយនៃសំណង់ជាដើម ដែលករណីនេះអាចឱ្យអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់រួចផុតពីការទទួលខុសត្រូវបាន ដោយសារតែការខូចខាតនោះបណ្តាលមកពីគ្រោះទឹកជំនន់ រញ្ជួយដី ឬខ្យល់ព្យុះដែលកើតឡើង។

### ២.៤.៣ ការកំណត់ពេល អំឡុងពេលបង្កើត និងរលត់អានុភាពនៃកិច្ចសន្យាលើសំណង់

ជាទូទៅកិច្ចសន្យាសាងសង់តែងតែបានកំណត់ពេលនៃការសាងសង់ច្បាស់លាស់ ហើយការទទួលខុសត្រូវក៏អាស្រ័យនឹងការធ្វើឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យា។ ភាគីនៃកិច្ចសន្យា អាចដាក់ល័ក្ខខ័ណ្ឌលើការបង្កើត ឬការរំលត់អានុភាពកិច្ចសន្យានោះ ក្នុងករណីដែលការដាក់ល័ក្ខខ័ណ្ឌរំលាយកាតព្វកិច្ច ឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា អានុភាពនៃកាតព្វកិច្ច ឬសិទ្ធិនោះត្រូវរលត់នៅពេលដែលល័ក្ខខ័ណ្ឌរំលាយនោះត្រូវបានបំពេញ[34]។ល័ក្ខខ័ណ្ឌរំលាយក៏គឺអាស្រ័យនឹងការកំណត់ពេលនៃកិច្ចសន្យាលើសំណង់នោះ ពីភាគីខាងកម្មសិទ្ធិករ និង អ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់ ។

ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះមិនត្រូវកើតឡើងរហូតដល់ពេលកំណត់នោះមកដល់។ ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា កម្មសិទ្ធិករមិនអាចទាមទារឱ្យអ្នកម៉ៅការសាងសង់ ឬក្រុមហ៊ុនសាងសង់អនុវត្តកាតព្វកិច្ច មុនពេលកំណត់បានឡើយ[35]។

[33] ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា, ២៦ មេសា ២០១៧, ប្រការ ៤ ។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣២៥ ។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣២៩ ។

អំឡុងពេលបង្កើតនៃកិច្ចសន្យាលើសំណង់ សំដៅដល់ការកំណត់ អំឡុងពេលនៃកាតព្វកិច្ចរបស់គូភាគី ក្នុងកិច្ចសន្យាដោយកំណត់ ជាម៉ោង នាទី វិនាទី ថ្ងៃ សប្តាហ៍ ខែ ឬឆ្នាំបាន[36]។ រីឯការរលត់អានុភាពនៃកិច្ចសន្យាលើសំណង់វិញ សំដៅដល់ពេលវេលាជាក់លាក់ណាមួយដែលអានុភាពនៃកិច្ចសន្យានោះបានបញ្ចប់។

សរុបមកវិញនៅត្រង់ការលើកឡើងខាងលើពីការកំណត់ពេល អំឡុងពេលបង្កើត និងរលត់អានុភាពនៃកិច្ចសន្យាសាងសង់គឺបង្ហាញពីស្ថានភាពមួយដែលភាគីកម្មសិទ្ធិករបានព្រមព្រៀងគ្នាជាមួយអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់ដែលបានចែងពីកាតព្វកិច្ចក្នុងការទទួលខុសត្រូវរបស់គូភាគី។ ប្រសិនបើល័ក្ខខ័ណ្ឌនៃកិច្ចសន្យាលើសំណង់នោះបានអនុវត្តចប់សព្វគ្រប់ដូចជាទៅលើការធានាលើគុណភាព បច្ចេកទេសសំណង់ពីសំណាក់អ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់នោះ មានវិការៈណាមួយកើតឡើងចេញពីសំណង់ជាប់នឹងដីកម្មសិទ្ធិករជាអ្នកដែលទទួលខុសត្រូវលើព្យសនកម្មនោះទៅលើជនរងគ្រោះ ហេតុថាកម្មសិទ្ធិករបានឯកភាពលើការធានាចំពោះគុណភាព ឬបច្ចេកទេសសំណង់រួចហើយ។ ដូចនេះអ្នកម៉ៅការសំណង់ ឬក្រុមហ៊ុនសាងសង់នឹងត្រូវរួចផុតពីការទទួលខុសត្រូវផ្អែកលើការរលត់អានុភាពនៃកិច្ចសន្យាសាងសង់។

### ២.៤.៤ អសមត្ថភាពនៃការទទួលខុសត្រូវ

ចំពោះអសមត្ថភាពនៃការទទួលខុសត្រូវវិញ សំដៅដល់ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានទទួលខុសត្រូវលើអំពើអនីត្យានុកូលដែលខ្លួនបានប្រព្រឹត្តទេ។ ហើយបុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកស្មារតី ឬមូលហេតុផ្សេងៗទៀត មិនត្រូវបានទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបានឡើយ។ ប៉ុន្តែមិនត្រូវបានរួចផុតពីការទទួលខុសត្រូវទេ ចំពោះករណីដែលស្ថានភាពនោះបណ្តាលមកដោយកំហុសចេតនា ឬអចេតនា។[37]

ដូចនេះប្រសិនបើជនដែលបង្កបានចូលទៅក្នុងល័ក្ខខ័ណ្ឌណាមួយនៃចំណុចខាងលើ ជនបង្កនោះនឹងត្រូវបានការការពារដោយច្បាប់ ព្រមទាំងរួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កឡើងដោយសំណង់ចាប់នឹងដីបាន។

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣២ ។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៥ ។

# ជំពូកទី៣
# ការទាមទារព្យសនកម្មដែលអាចកើតមានឡើង

ជាទូទៅវិធីសាស្ត្រដែលមានក្នុងការដោះស្រាយនូវបញ្ហានានា តែងតែមាននូវការបញ្ចប់នូវរឿងដែលបានជួបប្រទះនោះទៅតាមទម្រង់នីមួយៗគ្រាន់តែនៅក្នុងការដោះស្រាយនោះ គឺអាស្រ័យទៅលើទស្សនៈរបស់បុគ្គលជាអ្នកសម្រេចចិត្តជ្រើសរើសផ្ទាល់។ ក៏ដូចគ្នានេះដែរ ការទាមទារព្យសនកម្ម ឬការទាមទារសំណងការខូចខាតទៅលើអំពើអនីត្យានុកូលដែលបង្កឡើងដោយសំណង់ គឺបានដើម្បីអោយជនបង្ក ឬជនដែលបានប្រព្រឹត្តខុសបានចូលរួមចែករំលែកដោយយុត្តិធម៌ ក្នុងការខូចខាតដែលពួកគេបានបង្កមកលើជនរងគ្រោះ តាមរយៈការជួសជុលព្យសនកម្មជូនទៅដល់ជនរងគ្រោះ និងអ្នករងគ្រោះពោលគឺទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកស្មារតី។ លើសពីនេះជនរងគ្រោះ និងអ្នកដែលបានទទួលរងពីអំពើអនីត្យានុកូលទាំងឡាយ មានសិទ្ធិទាមទារឲ្យជនបង្កសងជាសំណងការខូចខាតដែលបង្កដោយសំណង់ជាប់នឹងដី តាមរយៈការទាមទារព្យសនកម្មក្រៅប្រព័ន្ធតុលាការ ឬប្រសិនបើការចរចាទាំងឡាយនោះជនរងគ្រោះ និងអ្នករងគ្រោះមិនសុខចិត្តអាចទាមទារព្យសនកម្មបានតាមផ្លូវតុលាការដែលមានសមត្ថកិច្ចជាអាជ្ញាកណ្តាលស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់។

## ៣.១ ការទាមទារព្យសនកម្មក្រៅផ្លូវតុលាការ

ការដោះស្រាយគ្នារវាងភាគីដែលបានពាក់ព័ន្ធទាំងឡាយក្នុងនោះ ការទាមទារព្យសនកម្មលើអំពើអនីត្យានុកូលបង្កដោយសំណង់ក្នុងលក្ខណៈនៅក្រៅប្រព័ន្ធតុលាការ គឺជាការដោះស្រាយនូវវិវាទមួយផ្អែកដោយមិនឆ្លងកាត់នីតិវិធីតុលាការ ឬ អាចជាជម្រើសដ៏ល្អប្រសើរមួយរបស់គូភាគីវិវាទដែលបានឯកភាពគ្នាធ្វើការដោះស្រាយវិវាទដោយមិនចូល ឬមុនចូលទៅតុលាការ។ នៅក្នុងវិធីសាស្ត្រដោះស្រាយវិវាទខាងលើគឺជាការជ្រើសរើសរបស់គូភាគីវិវាទក្នុងការដោះស្រាយណាមួយដោយមិនឆ្លងកាត់តុលាការហើយទាមទារឱ្យគូភាគីត្រូវតែព្យាយាមដោះស្រាយដោយសន្តិវិធីដើម្បីទទួលបានជោគជ័យ។[38] ប៉ុន្តែការដោះស្រាយនេះ មិនមែនជាជម្រើសចុងក្រោយបង្អស់របស់គូភាគីវិវាទឡើយ ព្រោះគូភាគីវិវាទអាចជ្រើសរើសនូវការដោះស្រាយវិវាទតាមផ្លូវតុលាការដោយផ្ទាល់ បន្ទាប់ពីការទាមទារព្យសនកម្មគូភាគីមានការខ្វែងគំនិតគ្នា ឬដោយប្រការណាមួយ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំទៅដោយទម្រង់ជាច្រើននៃវិធីដោះស្រាយវិវាទ[39] យ៉ាងណាមិញនៅក្នុងការទាមទារព្យសនកម្មក្រៅផ្លូវតុលាការទៅលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីដែលអាចកើតមានគឺមានតែ ការចរចា និងសន្ទានកម្ម។

---

[38] លោក កៅ សីហា, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ២០១០, ២ ។

[39] លោក ស៊ីវិន អ៊ែម អូស្ទើរមើឡឺរ, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ៣, ២០១០។

### ៣.១.១ ការចរចា

ការចរចា គឺជាវិធីសាស្ត្រដោះស្រាយមួយដែលភាគីទាំងឡាយ ឬតំណាងរបស់គេប្រើការអន្ទង និងការធ្វើសម្បទានដើម្បីដោះស្រាយវិវាទដោយផ្ទាល់រវាងពួកគេដោយគ្មានជំនួយពីភាគីទីបីឡើយ។ ការចរចារ ជាដំណើរការមួយដែលភាគីពាក់ព័ន្ធក្នុងវិវាទព្យាយាមដោះស្រាយបញ្ហាដោយការពិភាក្សាផ្ទាល់រវាងពួកគេ។ ក្នុងដំណើរការនេះភាគីនីមួយៗព្យាយាមពន្យល់ពីអ្វីដែលពួកគេចង់បានជាក់ស្តែង ដូចជាការទាមទារព្យសនកម្មពីជនបង្កជាដើម ឬ ត្រូវការឱ្យភាគីម្ខាងទៀតព្រមព្រៀងដោះស្រាយវិវាទដោយវិធីដ៏ពេញចិត្តបំផុត។ ការចរចារ គឺជាវិធីដំបូង និងជាទម្រង់ដ៏ទូទៅបំផុតនៃវិធីដោះស្រាយវិវាទយ៉ាងច្រើនបំផុតត្រូវបានដោះស្រាយ។ ការចរចារមានភាពជោគជ័យយ៉ាងណានោះ គឺទាមទារឱ្យគូភាគីវិវាទត្រូវធ្វើការដោះស្រាយដោយសន្តិវិធី និងការយោគយល់គ្នា។

ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនយ៉ាងដូចជា តាមរយៈផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីទាំងសងខាង ឬតាមរយៈតំណាងរបស់ភាគីនោះ។ ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណីមាត្រា៩៧ ក៏គាំទ្រឱ្យមានការចរចា និងលើកទឹកចិត្តឱ្យមានការស្រុះស្រួលគ្នាតាមការចរចារវាងភាគីទាំងពីរ។ បើប្រៀបធៀបជាមួយវិធីសាស្ត្រទូទៅផ្សេងទៀតនៃដំណោះស្រាយវិវាទ ការចរចាមានអត្ថប្រយោជន៍សំខាន់ៗមួយចំនួនដូចជា[40] សន្សំសំចៃការចំណាយ(៣.១.១.១) ភាពឯកជន(៣.១.១.២) កាត់បន្ថយពេលវេលាក្នុងការចរចារ(៣.១.១.៣) និងការរក្សាទំនាក់ទំនងបន្ត(៣.១.១.៤) ។

#### ៣.១.១.១ សន្សំសំចៃការចំណាយ

ការចរចាចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត។ នេះគឺជាចំណែកមួយដែលនាំឱ្យការចរចារមានប្រជាប្រិយភាពក្នុងសង្គម។ វាមិនមានប្រាក់ប្រដាប់ក្តី ឬថ្លៃចំណាយផ្សេងទៀតឡើយ និងទទួលបានផលចំណេញចំពោះភាគីទាំងសងខាង។

#### ៣.១.១.២ ភាពឯកជន

ការចរចារអាចជាដំណើរការឯកជនទាំងស្រុង ដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ។ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ។[41]

#### ៣.១.១.៣ កាត់បន្ថយពេលវេលាក្នុងការចរចារ

ការចរចាក្នុងការដោះស្រាយបញ្ហា ក៏ដូចជាការទាមទារព្យសនកម្ម អាចនឹងត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធិភាព។ ភាគីមិនចាំបាច់ត្រូវរង់ចាំចៅក្រម ឬសន្ធានការី ដើម្បីធ្វើសវនការ និងសម្រេចលើរឿងក្តីនោះឡើយ។ បញ្ហាអាចនឹងត្រូវដោះស្រាយភ្លាមៗ ឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា។

[40] លោក ស៊ីវិន អ៊ែម អូស្មើរមើឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ១៥, ២០១០។

[41] លោក កៅ សីហា, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ៣, ២០១០ ។

### ៣.១.១.៤ ការរក្សាទំនាក់ទំនងបន្ត

ការចរចារផ្តល់នូវលទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលណាមួយដែលអាចរក្សាទំនាក់ទំនងនេះបានដែលពួកគេធ្លាប់មានពីមុនមក។ ឧទាហរណ៍ ប្រសិនបើម្ចាស់សំណង់ និងជនរងគ្រោះ ឬអ្នករងគ្រោះដែលមានវិវាទជាមួយ ធ្លាប់រាប់អានគ្នាពីមុនមកនោះ ការជ្រើសរើសយកវិធីសាស្ត្រចចាក៏អាចធ្វើអោយទំនាក់ទំនងភាគីទាំងអស់មិនត្រូវបានបំផ្លាញ ប្រសិនបើការចរចារនោះអាចទទួលយកបានពីគូភាគី។

### ៣.១.២ សន្ធានកម្ម

សន្ធានកម្ម គឺជាការដោះស្រាយវិវាទមួយទៀតដោយឈរលើដំណើរការនៃការចរចា។ នៅក្នុងសន្ធានកម្ម ឬយើងអាចហៅម្យ៉ាងទៀតឱ្យងាយស្រួលយល់ថាជា "ការសម្រុះសម្រួល" ភាគីអព្យាក្រឹត្យទីបីម្នាក់ ឬច្រើននាក់ ហៅថា "សន្ធានការី ឬអ្នកសម្រុះសម្រួល" ជួយភាគីទាំងឡាយដើម្បីដោះស្រាយវិវាទរបស់ពួកគេផ្ទាល់ សន្ធានការី មិនមានអំណាចទៅលើគូភាគីក្នុងការបង្ខិតបង្ខំ ឱ្យពួកគេទទួលយកនូវដំណោះស្រាយរបស់ខ្លួនឡើយ មានន័យថា អ្នកសម្រុះសម្រួលមិនអាចធ្វើសេចក្តីសម្រេចបានឡើយ ។ សន្ធានការីព្យាយាមបង្កើតស្ថានភាពដែល ភាគីទាំងឡាយអាចសម្រេចការដោះស្រាយដោយពួកគេផ្ទាល់ ។ ដំណើរការសម្រុះសម្រួល គឺស្រដៀងគ្នាណាស់ទៅ នឹងការផ្សះផ្សាតាមប្រពៃណី ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា (នីតិវិធីផ្សះផ្សារបស់ចៅក្រមតុលាការ) ។ ជាទូទៅសន្ធានកម្មកើតឡើងបន្ទាប់ពីភាគីទាំងឡាយព្យាយាមចរចារវាងពួកគេ ប៉ុន្តែមិនអាចសម្រេចរកដំណោះស្រាយមួយបាន ។ ដូចនេះការសម្រុះសម្រួលនៅក្នុងការដោះស្រាយវិវាទត្រូវតែមានការចូលរួមពីភាគីទីបី ដែលជា សន្ធានការី ឬអ្នកសម្រុះសម្រួល ។

គោលបំណងខ្ពស់បំផុតរបស់សន្ធានការី គឺជួយភាគីទាំងឡាយដើម្បីដោះស្រាយវិវាទប្រកបដោយមេត្រីភាព។ ដើម្បីសម្រេចគោលបំណងនេះបាន អ្នកសម្រុះសម្រួលអាចធ្វើតាមចំណុចខ្លះៗដូចខាងក្រោម៖

ជួយបន្ថយប្រទូសភាពនិងភាពតានតឹងរវាងភាគីទាំងឡាយដោយលើកទឹកចិត្តឲ្យមានការសហប្រតិបត្តិការណ៏ ។

ជួយភាគីទាំងសងខាងឱ្យផ្តោតអារម្មណ៏ទៅលើបញ្ហាទាំងឡាយដែលចាំបាច់ត្រូវដោះស្រាយវិវាទ។

ការទាក់ទងរវាងភាគីទាំងឡាយ ប្រសិនបើភាគីទាំងនោះមិននិយាយផ្ទាល់ទៅវិញទៅមក ។

ជួយភាគីម្នាក់ៗឱ្យយល់ពីប្រយោជន៍ទាំងឡាយរបស់ភាគីម្ខាងទៀត ។

ជួយភាគីទាំងអស់ឱ្យរកដំណោះស្រាយមួយផ្សេងទៀត ។

ផ្តល់ពីវិធីប្រាកដនិយម និងសត្យានុម័តសម្រាប់ឱ្យភាគីទាំងឡាយធ្វើការវិភាគទៅលើផលប្រយោជន៍និងការផ្តល់ ឱ្យរបស់ភាគីទាំងនោះ ។

## ៣.២. ការទាមទារព្យសនកម្មតាមផ្លូវតុលាការ

តុលាការ គឺជាស្ថាប័នឯករាជ្យមួយដែលមានអំណាចក្នុងការធានារក្សាអនាគតិ ព្រមទាំងការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ ហើយរួមចំណែកពង្រឹងសុវត្ថិភាពសង្គម។ អំណាចតុលាការត្រូវបានអនុវត្តតាមរយៈសាលាជម្រះក្តីដែលត្រូវបានបែងចែកជាពីរជាន់ គឺសាលាជម្រះក្តីជាន់ទាប ជាសាលាដំបូង ហើយ សាលាជម្រះក្តីជាន់ខ្ពស់ ជាសាលាឧទ្ធរណ៍ និងតុលាការកំពូល។[42]

ប្រព័ន្ធច្បាប់ បានផ្តល់នូវភាពចាំបាច់ក្នុងការដោះស្រាយទំនាស់ជាច្រើន។ ទោះជាយ៉ាងណាជម្លោះមួយចំនួននឹងមិនឈានដល់កិច្ចព្រមព្រៀងតាមរយៈការសម្របសម្រួលគ្នាឡើយ។ ជម្លោះមួយចំនួនត្រូវការអំណាចបង្ខិតបង្ខំរបស់រដ្ឋដើម្បីពង្រឹងដំណោះស្រាយមួយ។ មនុស្សត្រូវការអ្នកមានជំនាញ មានវិជ្ជាជីវៈ ដើម្បីជួយដោះស្រាយពួកគេ ពេលដែលពួកគេជួបបញ្ហា ប្រសិនបើជម្លោះនោះទាក់ទងនឹងការរំលោភសិទ្ធិស្របច្បាប់ ការធ្វើខុសច្បាប់ឬការគំរាមកំហែងនៃការសកម្មភាពផ្លូវច្បាប់ ប្រឆាំងនឹងពួកគេ។ អ្នកដែលដោះស្រាយដោយមិនលំអៀងគឺចៅក្រម ដោយផ្អែកលើអង្គហេតុនៃរឿងក្តីនេះនិងច្បាប់ ។ ជាក់ស្តែងវិធីសាស្ត្រទាមទារព្យសនកម្មលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីនេះ គឺជាការទាមទារព្យសនកម្មតាមផ្លូវតុលាការ ដោយចេញពីទំនាស់កើតឡើងនៅពេលដែលភាគីម្ខាងមិនសុខចិត្តនឹងភាគីម្ខាងទៀត។ ប៉ុន្តែនៅត្រង់ចំណុចការទាមទារព្យសនកម្មតាមផ្លូវតុលាការនេះនឹងមិនបានធ្វើការលើកយកសិក្សាលម្អិតទៅលើនីតិវិធីក្នុងការទាមទារសំណងការខូចខាតនោះទេពោលគឺនឹងលើកយកមកបកស្រាយពីទម្រង់ពាក្យបណ្តឹង និងការដាក់ពាក្យបណ្តឹងតែប៉ុណ្ណោះ។

### ៣.២.១. ទម្រង់ពាក្យបណ្តឹង

បណ្តឹង សំដៅលើសកម្មភាពទាមទារមួយដែលធ្វើឡើងដោយភាគីដើមចោទចំពោះចុងចម្លើយទៅកាន់តុលាការនៃការជំនុំជម្រះក្តីដោយអះអាងអំពីអត្ថភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយដោយផ្អែកទៅលើការអះអាងនានា។ ការដាក់ពាក្យបណ្តឹងអាចជាជនរងគ្រោះដែលជាសាមីខ្លួនផ្ទាល់ ឬ អ្នករងគ្រោះដែលមាន សាច់ញាតិ បងប្អូន និងឪពុកម្តាយ អ្នកមានជាប់ខ្សែលោហិតនឹងជនរងគ្រោះ។ អ្នករងគ្រោះ អាចដាក់ពាក្យជំនួសបាន ប្រសិនបើជនរងគ្រោះមិនអាចធ្វើដោយខ្លួនឯងបានក្រោយពីជួបប្រទះករណីអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី។ បណ្តឹងលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីនេះ មានគោលបំណងធ្វើឱ្យមានការជុសជុល កំហូចដែលបណ្តាល មកពីអំពើល្មើសដល់ភាគីរងគ្រោះហើយក្នុងគោលបំណងនេះអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់។

[42] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខនស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ១ និង មាត្រា ៣។

ទោះបីជាបណ្តឹងត្រូវបានធ្វើឡើងដោយភាគីខ្លួនឯងក្តី ឬធ្វើឡើងដោយអ្នកតំណាងរបស់ខ្លួនក្តី (មេធាវី) ក៏ពាក្យបណ្តឹងទាំងនោះចាំបាច់ត្រូវតែគោរពតាមវិធានដែលបានកំណត់អំពីចំណុចផ្សេងៗត្រូវសរសេរនៅក្នុងពាក្យបណ្តឹងដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។[43] ការដែលត្រូវបានយល់ដឹងអំពីវិធាននេះ គឺពិតជាបានផ្តល់នូវសារៈប្រយោជន៍ណាស់ ព្រោះការដែលធ្វេសប្រហែសក្នុងការអនុវត្តតាមវិធាននេះអាចធ្វើឱ្យតុលាការបង្គាប់ឲ្យធ្វើការកែតម្រូវលើពាក្យបណ្តឹង ឬឈានដល់ការលើកចោលនូវពាក្យបណ្តឹងបាន។ ទម្រង់ពាក្យបណ្តឹងមានដូចជា ឈ្មោះ និងអាសយដ្ឋានរបស់ភាគី(៣.២.១.១) កម្មវត្ថុនៃបណ្តឹងការទាមទារ(៣.២.១.២) អង្គហេតុនៃការទាមទារ(៣.២.១.៣) កាលបរិច្ឆេទនៃការប្តឹង(៣.២.១.៤) និងស្នាមមេដៃ ឬហត្ថលេខា(៣.២.១.៤)។

#### ៣.២.១.១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគី

ភាគី គឺជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្តឹងដើម្បីបញ្ជាក់ថា អ្នកណាជាដើមចោទ ហើយអ្នកណាជាចុងចម្លើយ ។ ត្រង់ចំណុចដើមចោទ និងចុងចម្លើយនេះ គឺ ដើមចោទ ជាជនរងគ្រោះ ឬអ្នករងគ្រោះ រីឯចុងចម្លើយ គឺជាចារី។ ប្រសិនជារូបវន្តបុគ្គលត្រូវសរសេរឈ្មោះបុគ្គលនោះ ព្រមទាំងអាសយដ្ឋានឲ្យបានច្បាស់លាស់ តែបើជានីតិបុគ្គលវិញ ត្រូវសរសេរនាមករណ៍ ឬឈ្មោះ និងទីតាំងនៃទីស្នាក់ការទីតាំងនៃនីតិបុគ្គល និងអត្តសញ្ញាណនៃអ្នកតំណាង។ មូលហេតុដែលបញ្ជាក់រាល់ចំណុចដែលភាគីមាន គឺដើម្បីបង្កនូវភាពងាយស្រួលឲ្យភាគីម្ខាងទៀតបានដឹង។

#### ៣.២.១.២. កម្មវត្ថុនៃបណ្តឹងការទាមទារ

ក្នុងពាក្យបណ្តឹង ដើមចោទត្រូវបញ្ជាក់ឲ្យនូវមូលហេតុ ដែលទទួលរងព្យសនកម្ម ដោយសារតែជនបង្កបានធ្វេសប្រហែស មិនប្រុងប្រយ័ត្នដោយចេតនាក្តី ឬអចេតនាក្តី និងតាមប្រការណាមួយក្តី ជាហេតុបណ្តាលឲ្យមានអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី ព្រមទាំងអំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ជាប់នៃសាលក្រមដែលខ្លួនទាមទារ។ ការសរសេរពីសាលក្រមដែលទាមទារឲ្យតុលាការចេញនេះត្រូវធ្វើឡើងឲ្យបានលម្អិត និងឲ្យបានច្បាស់លាស់ ដូចជា ការសរសេរបង្គាប់ឲ្យចុងចម្លើយបង់សំណងការខូចខាតជាដើម។

#### ៣.២.១.៣. អង្គហេតុនៃការទាមទារ

អង្គហេតុនៃការទាមទារ គឺជាអង្គហេតុចម្បងដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទដែលជួយបញ្ជាក់អំពីអត្ថភាព ឬនត្ថិភាពនៃសិទ្ធិទាមទារឲ្យកាន់តែច្បាស់លាស់។ ជាទូទៅអង្គហេតុនៃការទាមទារ ឬអង្គហេតុចម្បងបានដើរតួនាទីយ៉ាងសំខាន់ដែលនឹងអាចឲ្យតុលាការ

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៧៥។

ធ្វើការពិចារណាដោយផ្អែកលើភស្តុតាងអង្គហេតុនោះថាតើអង្គហេតុនោះបានបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងដែរ ឬទេ ដើម្បីអាចឲ្យតុលាការទទួលស្គាល់នូវអង្គហេតុដែលគូភាគីលើកឡើង។[44]

ឧទាហរណ៍៖ ចុងចម្លើយដែលជាម្ចាស់សំណង់នៃអាគារ ត្រូវបានរកឃើញថាប្រភពនៃអគ្គីភ័យគឺបានបណ្តាលមកពីអាគាររបស់ចុងចម្លើយ ដែលធ្វើអោយហាងលក់ទំនិញរបស់ដើមចោទនៅក្បែរអាគារនោះខូចខាតទាំងស្រុង។ ដើមចោទដាក់ពាក្យប្តឹងទៅតុលាការផ្អែកលើអំពើអនីត្យានុកូលក្នុងការទាមទារព្យសនកម្មដោយបណ្តាលអោយហាងទំនិញរបស់ខ្លួនត្រូវបានអគ្គីភ័យលេបត្របាក់តាមរយៈការធ្វេសប្រហែស កង្វះនៃការគ្រប់គ្រងមិនប្រុងប្រយ័ត្នពីចុងចម្លើយបង្ក។

តាមរយៈការបញ្ជាក់ទាំងនេះ គឺបានច្បាស់លាស់នូវកម្មវត្ថុនៃសិទ្ធិ(សាច់រឿងពិតចំពោះសិទ្ធិលើអង្គហេតុដែលដាក់ឲ្យជំនុំជម្រះ) ប្រភេទ(អំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី) និងខ្លឹមសារនៃសិទ្ធិ(សិទ្ធិក្នុងការទាមទារសំណងព្យសនកម្ម) ព្រមទាំងមូលហេតុនៃការកកើតសិទ្ធិ(បង្កអោយមានការខូចខាតដល់ជនរងគ្រោះ) គឺអាចបញ្ជាក់ឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទបាន។

#### ៣.២.១.៤. កាលបរិច្ឆេទនៃការប្តឹង

ក្នុងការទទួលស្គាល់នូវសុពលភាពនៃពាក្យបណ្តឹង និងដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចវិវាទឲ្យ ទាន់ពេលវេលា ហើយការពារនូវការអាក់អន្លូលនៃកាលបរិច្ឆេទនៃការប្តឹង ក្រៅពីការសរសេរបញ្ជាក់អំពីសាលក្រម ដែលទាមទារឲ្យតុលាការចេញ និងអង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារគប្បីសរសេរឲ្យបានលម្អិត ពីអង្គហេតុដែលជាមូលហេតុនៃការទាមទារព្រមទាំងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ និងភស្តុតាង តាមចំណុចដែលបានបញ្ជាក់។[45]

#### ៣.២.១.៥. ស្នាមមេដៃ ឬហត្ថលេខា

ស្នាមមេដៃ ឬ ហត្ថលេខា គឺជាភស្តុតាងយ៉ាងសំខាន់បំផុតក្នុងការបញ្ជាក់ពីព័ត៌មានដែលជនរងគ្រោះបានដាក់ ពាក្យទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីឲ្យកាន់តែច្បាស់ទៅទៀតថា អ្វីទាំងនោះជា ការពិតដែលនឹងត្រូវបញ្ជាក់ដោយជនរងគ្រោះ ។ រីឯ ភ័ស្តុតាង ភាគីត្រូវ ដាក់ជាឯកសារ ឬ លិខិត (ច្បាប់ដើម) ពុំអាចដាក់លិខិតថតចម្លងបានឡើយ ដោយហេតុថានៅពេលដែលប្រើប្រាស់នូវលិខិតថតចម្លង អាចមាននូវវិការៈផ្សេងៗកើតមានឡើង។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ១២៣។

[45] សេចក្តីពន្យល់ អំពីចំណុចសំខាន់ៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម (គន្លី ១ ដល់គន្លី ៥, គន្លី៨ ដល់គន្លី៩), ៣៥-៤០។

### ៣.២.២. ការដាក់ពាក្យបណ្ដឹង

ការដាក់ពាក្យបណ្ដឹងអាចជាជនរងគ្រោះដែលជាសាមីខ្លួនផ្ទាល់ ឬ អ្នករងគ្រោះដែលមាន សាច់ញាតិ បងប្អូន និងឪពុកម្ដាយ អ្នកមានជាប់ខ្សែលោហិតនឹងជនរងគ្រោះ។ អ្នករងគ្រោះ អាចដាក់ពាក្យជំនួសប្រសិនបើជនរងគ្រោះ មិនអាចធ្វើដោយខ្លួនឯងបានក្រោយពីជួបប្រទះដោយអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី។ បណ្ដឹងលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដីនេះ មានគោលបំណងធ្វើឱ្យមានការជុសជុល កំហូចខាតដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះហើយក្នុងគោលបំណងនេះអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់។ ហើយនៅក្នុងការដាក់ពាក្យបណ្ដឹងនេះនឹងបង្ហាញដូចជា សមត្ថកិច្ចសាលាជម្រះក្ដី(៣.២.២.១) និង ការបង់ពន្ធលើពាក្យសុំ(៣.២.២.២)។

#### ៣.២.២.១. សមត្ថកិច្ចសាលាជម្រះក្ដី

សមត្ថកិច្ចសាលាជម្រះក្ដី គឺជាសាលាជម្រះក្ដីដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះរឿងក្ដីនីមួយៗផ្សេងៗគ្នាទៅតាមប្រភេទនៃបញ្ហាដែលបានកើតឡើង។ យោងតាមច្បាប់[46] បានឱ្យនិយមន័យ សមត្ថកិច្ចសាលាជម្រះក្ដីជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្ដី ហើយចេញសាលក្រម ឬ សាលដីកាបាន។

យ៉ាងណាវិញសមត្ថកិច្ចក្នុងរឿងអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី គឺជាសមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិ ព្រោះថាសំណង់ជាប់នឹងដីទាំងឡាយដែលបានបង្កឱ្យមានអំពើអនីត្យានុកូល គឺស្ថិតនៅទីតាំងណាមួយច្បាស់លាស់ដែលបានប៉ះពាល់ទៅដល់ជនរងគ្រោះផ្ទាល់ ហើយជាបណ្ដឹងទាក់ទងនឹងអំពើអនីត្យានុកូល មានន័យថា ជាកន្លែងដែលអំពើអនីត្យានុកូលកើតឡើង[47] ។ សមត្ថកិច្ចនេះ គឺជាសមត្ថកិច្ចដែលបានផ្ដល់ឱកាសដល់អ្នកដែលបានដាក់ពាក្យបណ្ដឹងនៅទីតាំងកើតហេតុផ្ទាល់។

#### ៣.២.២.២. ការបង់ពន្ធលើពាក្យសុំ

ការបង់ពន្ធត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ ហើយពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់នោះទេ ត្រូវចាត់ទុកជាពាក្យសុំមិនស្របច្បាប់ ។[48]

នៅពេលដាក់ពាក្យបណ្ដឹងទៅតុលាការ ដើមចោទត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្ដឹងដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដល់ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀលត្រូវបង់ ១.០០០ (មួយពាន់) រៀល។ ប៉ុន្តែក្នុងករណីដែលមានការពិបាកក្នុង

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៧ ។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៩, ចំណុច ច ។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៦១,កថាខណ្ឌទី ៧ ។

ការគណនាតម្លៃគឺតុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល។[49] ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០.០០០.០០០ (ដប់លាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀលក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៧០០ (ប្រាំពីររយ) រៀល។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៣០០ (បីរយ) រៀល។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងលើស ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១០០ (មួយរយ) រៀល។ ចំពោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបង់ពន្ធ ១,៥ ដង (មួយកៀ្បសប្រាំដង) រីឯចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខវិញ ត្រូវបង់ពន្ធ ២ ដង (ពីរដង) នៃថ្លៃពន្ធដែលបានគណនាយោងទៅតាមភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលបានរៀបរាប់ខាងលើ នេះទៅតុលាការ។ ចំពោះការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវបង់ ១០.០០០ (មួយម៉ឺន) រៀលទៅតុលាការ។ ចំពោះការដាក់ពាក្យសុំចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធចំនួន ១ភាគ២ នៃប្រាក់ដោយគណនារួច ទៅតាមតម្លៃកម្មវត្ថុនៃការទាមទារ។ ការដែលបង់ពន្ធលើស សងពន្ធដែលបានបង់លើសទៅវិញ ក្នុងករណីដែលមានការផ្សះផ្សាបានលទ្ធផលមុនពេលការទាញហេតុផលផ្ទាល់មាត់។ ករណីដែលដកបណ្តឹងមុនពេលចប់កាលបរិច្ឆេទ នៃការទាញហេតុផលផ្ទាល់មាត់លើកដំបូង ករណីដែលសេចក្តីសម្រេចលើកចោលពាក្យបណ្តឹងសដោយមិនបានឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ចូលជាស្ថាពរ គឺសងពាក់កណ្តាលនៃពន្ធដែលបានបង់ហើយទៅឱ្យដើមចោទវិញ។[50]

### ៣.២.៣. អាជ្ញាយុកាលនៃសិទ្ធិទាមទារសំណងការខូចខាត

ទោះបីជាច្បាប់បានផ្តល់នូវការការពារទៅឱ្យជនរងគ្រោះ និងអ្នករងគ្រោះពីអំពើអនីត្យានុកូលអាចមានសិទ្ធិទាមទារសំណងព្យសនកម្មបាន។ យ៉ាងណាមិញសិទ្ធិទាមទារនេះក៏ត្រូវបានចាត់ទុកជាអសាបង់ ឬបាត់បង់សិទ្ធិទាមទារនេះវិញប្រសិនបើមិនបានគោរពទៅតាមពេលកំណត់របស់ច្បាប់ទាន់ពេល។អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងសំដៅទៅលើការរំលត់សិទ្ធិទាមទារសំណងដោយផ្អែកលើការណ៍ ដែលអ្នកមានសិទ្ធិទាមទារមិនអនុវត្តសិទ្ធិនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។[51] ប្រៀបធៀបជាមួយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងមានអំឡុងពេលខ្លីជាង ពោលគឺមានអំឡុងពេលតែ ៣(បី) ឆ្នាំ បន្ទាប់ពីពេលដែលជនរងគ្រោះ ឬតំណាង ដែលច្បាប់បានកំណត់របស់ជនរងគ្រោះបានដឹងថាអាចទាមទារសំណងការខូចខាតចំពោះ អ្នកប្រព្រឹត្តអំពើបំពាន

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៦០ ។
[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ២៣ មិថុនា ២០០៦, មាត្រា ៦១ ។
[51] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពី អំពើអនីត្យានុកូល, ៨២។

ពោលគឺបានដឹងអំពីការខូចខាត និងអត្តសញ្ញាណនៃជនប្រព្រឹត្តអំពើបំពាន ឬបើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូល ត្រូវបានប្រព្រឹត្តឡើង។ ពោលគឺ អ្នកមានសិទ្ធិក្នុងការទាមទារសំណងការខូចខាត ទើបតែនឹងបានដឹងអំពីសិទ្ធិក្នុងការទាមទារសំណងការខូចខាតក៏ដោយ ក៏សិទ្ធិនោះត្រូវរលត់ដោយអាជ្ញាយុកាលដែរ ប្រសិនបើ ផុតរយៈពេល ១០ (ដប់) ឆ្នាំ ក្រោយអំពើអនីត្យានុកូលនោះបានកន្លងផុតទៅរយៈពេលយូរហើយនោះ[52]។

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៧៦៥។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយទៅលើប្រធានបទ **"ការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កឡើងដោយសំណង់ជាប់នឹងដីនេះ"** មកឃើញថាប្រធានបទមួយនេះមានលក្ខណៈសមស្របទៅតាមបរិបទនា ពេលបច្ចុប្បន្ន ដែលជាបញ្ហាចំបងមួយពាក់ព័ន្ធនឹងសំណង់ជាប់ដីក្នុងប្រទេសកម្ពុជាយើង។ ដោយសារតែសង្គមតម្រូវឲ្យមាន ការរីកចម្រើន ការអភិវឌ្ឍន៍ទាំងវិស័យសេដ្ឋកិច្ច និង វិស័យដទៃទៀតប្រកបដោយសណ្តាប់ធ្នាប់ របៀបរៀបរយ ព្រមទាំងទាមទារឲ្យមានការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដោយមានទាំងរូបវ័ន្តបុគ្គល និងនីតិបុគ្គល។ តួយ៉ាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមួយប្រកាន់យកគោលការណ៍ច្បាប់ជាធំ ដោយប្រជាពលរដ្ឋគ្រប់រូបត្រូវតែ គោរពច្បាប់ដែលបានកំណត់ ហើយប្រសិនបើមានការប្រព្រឹត្តល្មើសច្បាប់ដោយចេតនាក្តី ឬអចេតនាក្តីត្រូវតែទទួលខុសត្រូវទៅលើព្យសនកម្មដែលខ្លួនបានបង្កឡើងជាដាច់ខាត។

ហេតុនេះ ការទទួលខុសត្រូវពិតជាមានសារៈសំខាន់ណាស់ចំពោះសង្គមជាតិ និងប្រជាពលរដ្ឋគ្រប់រូប។ ដូចនឹងអ្វីដែលបានរៀបរាប់ពីខាងដើមនៅពេលដែលមានការរីកចម្រើនកើតឡើងរមែងទាមទារឲ្យមានការកសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីបំពេញតម្រូវការដល់ការ រស់នៅ ការធ្វើអាជីវកម្ម ពាណិជ្ជកម្ម និងការកសាងនូវសំណង់ជាច្រើនដែលមានការរីកដុះដាលជាលំដាប់។ ទន្ទឹមនឹងនេះ អត្ថប្រយោជន៍ដែលបានមកពី ព្យសនកម្ម សំណង និងវិធីនៃការទាមទារព្យសនកម្ម ដែលកើតចេញពី សំណង់នេះ ក៏បានដើរទន្ទឹមគ្នាដែរ។ ដោយហេតុថាប្រជាពលរដ្ឋយើងមួយចំនួនពុំទាន់មានការ យល់ដឹងទូលំទូលាយអំពីការទទួលខុសត្រូវលើសំណង់ជាប់នឹងដីនេះ ទើបធ្វើឲ្យគេគិតថានៅពេល ដែលមានព្យសនកម្មកើតមានឡើងបង្កឲ្យមានការខូចខាតដោយសំណង់ជាប់នឹងដីបន្ទុកក្នុងការទទួលខុសត្រូវ គឺត្រូវធ្លាក់ទៅលើម្ចាស់កម្មសិទ្ធិករដែលជាអ្នកទទួលខុសត្រូវជានិច្ច ដែលផ្តល់នូវភាពអយុត្តិធម៌មិនត្រឹមត្រូវដល់ជនមិនបានប្រព្រឹត្ត។ ចំពោះការទទួលខុសត្រូវលើអំពើអនីត្យានកូលបង្កឡើងដោយសំណង់ជាប់នឹងដីមិនមែនមានតែកម្មសិទ្ធិករតែមួយនោះទេ ដែលជាអ្នកទទួលខុសត្រូវ តែមានការចូលរួមពីបុគ្គលផ្សេងទៀតដែលត្រូវទទួលខុសត្រូវ ហើយការទទួលខុសត្រូវត្រូវផ្អែកទៅលើ ល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ដាច់ដោយឡែកពីគ្នា។ ហើយនៅពេលដែលត្រូវទាមទារព្យសនកម្ម បានផ្តល់នូវគន្លឹះបន្ថែមដល់ជនរងគ្រោះ ឬអ្នករងគ្រោះអាចជ្រើសរើសការទាមទារទៅតាមវិធីដែលខ្លួនចង់បាន។ ដូចនេះអត្ថប្រយោជន៍នៃប្រធានបទនេះអាចជាផ្នែកមួយនឹងត្រូវបានបំភ្លឺចំពោះចម្ងល់របស់ប្រជាពលរដ្ឋយើង។ លើសពីនេះទៀតសំណង់ជាប់នឹងដីមិនមែនសំដៅតែទៅលើសំណង់ជា អាគារ ផ្ទះ ខុនដូ អាផាតមិន ស្ពាន អ្វីនោះទេ ពោលគឺសំដៅដល់សំណង់ជាច្រើនទៀតក៏ត្រូវបានចាត់ទុកថាជាសំណង់ជាប់នឹងដីដែរ។ ហើយបន្ថែមពីលើល័ក្ខខ័ណ្ឌជាគោលនៃអំពើអនីត្យានុកូលចំពោះការទទួលខុសត្រូវសំណង់ជាប់នឹងដីក៏មានល័ក្ខខ័ណ្ឌក្នុងករណីនីមួយៗបន្ថែមពីលើនេះទៀត។ ដូចនេះការទទួលខុសត្រូវលើសំណង់ជាប់នឹងដីទាមទារឲ្យពលរដ្ឋគ្រប់រូបត្រូវធ្វើការយល់

ដឹងឲ្យបានច្បាស់លាស់ និងទូលំទូលាយ ដើម្បីជៀសវាងការទាមទារសំណងខុសដែលនាំឲ្យខាតបង់នូវពេលវេលា និងលុយកាក់ក្នុងការទាមទារសំណងតាមនីតិវិធីផ្សេងៗរបស់តុលាការដូចជា ការបង់ពន្ធលើប្រាក់ប្រដាប់ក្តី បង់ពន្ធលើពាក្យបណ្តឹង រង់ចាំការសម្រេចពីតុលាការជាដើម។ លើសពីនេះទៅទៀតការដែលបានលើកឡើងអំពីសំណង់ជាប់នឹងដីក៏បានបន្ថែមនូវចំណុចពាក់ព័ន្ធនឹងការអនុញ្ញាតក្នុងការសាងសង់ដែល យោងទៅតាមអនុក្រឹត្យនៃលិខិតអនុញ្ញាតសាងសង់ ដែលអាចជាចំណុចមួយដើម្បីជាជំនួយដល់ការស្រាវជ្រាវផ្សេងៗផងដែរទាក់ទងនឹងដែនសមត្ថកិច្ចទៅតាមឋានានុក្រមក្នុងការស្នើសុំសាងសង់សំណង់នានា។

សរុបសេចក្តីមក ការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កដោយសំណង់ជាប់នឹងដី គឺជាបញ្ហាចំបងមួយដែលកំពុងតែជួបប្រទះនាពេលបច្ចុប្បន្ន ហើយក៏មានសារៈសំខាន់សម្រាប់សង្គម ទាមទារអោយប្រជាពលរដ្ឋ និង សង្គមជាតិទាំងមូលឲ្យមានស្មារតីភ្ញាក់រលឹក ទទួលខុសត្រូវ និងទទួលស្គាល់នូវកំហុសរបស់ខ្លួនផ្អែកលើការគោរពច្បាប់ ហើយមានសីលធម៌ សុជីវធម៌នៅក្នុងការរស់នៅ និងត្រូវចេះអធ្យាស្រ័យ យោគយល់គ្នាទៅវិញទៅមកនាពេលមានជម្លោះកើតឡើងបង្កដោយសំណង់ជាប់នឹងដី។

# អនុសាសន៍

ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវរបស់ ខ្ញុំកន្លងមកឃើញថា ការទទួលខុសត្រូវលើអំពើអនីត្យានុកូលបង្កឡើងដោយសំណង់ជាប់នឹងដីនៅក្នុងប្រទេសកម្ពុជា គឺកើតមានឡើងជាច្រើនក្នុងសង្គម ដោយបានបង្កឲ្យមាននូវការខូចខាតកើតមានទៅដល់បុគ្គលដែលជាជនរងគ្រោះលក្ខណៈគ្រប់ទម្រង់ ហើយនៅក្នុងករណីមួយចំនួនសំណងនៃព្យសនកម្មមិនមានលក្ខណៈស្របទៅតាមការកំណត់របស់ច្បាប់ទេ ដោយសារតែពេលខ្លះជនរងគ្រោះមិនទទួលបាននូវសំណង ព្យសនកម្មទៅតាមទំហំនៃការខូចខាតរបស់ខ្លួន ឬពេលខ្លះទំហំនៃសំណងព្យសនកម្មមិនសមាមាត្រ ទៅនឹងទំហំនៃការខូចខាតរបស់ជនរងគ្រោះ។

ម្យ៉ាងវិញទៀត បញ្ហាទាក់ទងទៅនឹងព្យសនកម្មដែលកើតឡើងដោយសំណង់ជាប់នឹងដីនេះ ជាផលវិបាកមួយដែលកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្ន ហើយក៏បានហុចនូវផល អវិជ្ជមានដែរ ដោយហេតុថាទំហំនៃព្យសនកម្មរបស់វាមានការប៉ះពាល់ខ្លាំងទៅដល់ជនរងគ្រោះជាច្រើននាក់ដែលយើងមិនគួរមើលរំលង។ រាជរដ្ឋាភិបាល ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធគួរតែចាត់ វិធានការទៅលើបញ្ហាមួយនេះឲ្យបានជាក់លាក់ ដើម្បីធានាទៅដល់សុខសុវត្ថិភាពរបស់ប្រជាជន និងដើម្បីបង្ការកុំឲ្យមាននូវហានិភ័យគ្រោះថ្នាក់ណាមួយកើតមានឡើង ដោយសារតែសំណង់ជាប់នឹងដីនេះដែរ។ មិនតែប៉ុណ្ណោះគួរតែបង្កើតឲ្យមាននូវបញ្ញត្តិច្បាប់ ឬវិធានការគ្រប់គ្រងឲ្យបានតឹងរ៉ឹង និងមានភាពច្បាស់លាស់ពាក់ព័ន្ធនឹងការទទួលខុសត្រូវទៅលើសំណងព្យសនកម្មដែលកើតមាន ឡើងដោយសារតែសំណង់នេះដើម្បីឲ្យជនរងគ្រោះទទួលបាននូវសំណងនៃការខូចខាតពីជនដែលបង្កឡើងដោយសមរម្យ និងស្របទៅតាមការកំណត់របស់ច្បាប់។

ក្រៅពីនេះទៅទៀត បុគ្គលគ្រប់រូបមិនថារូបវន្តបុគ្គល ឬនីតិបុគ្គលនោះទេក៏គួររួមចំណែកនៅ ក្នុងបញ្ហាមួយនេះដោយគួរតែមានការប្រុងប្រយ័ត្ន និងគោរពទៅតាមការកំណត់របស់ច្បាប់នៅក្នុង ការសាងសង់សំណង់ដើម្បីជួយបង្ការ និងកាត់បន្ថយនូវការកើតឡើងនូវការខូចខាតណាមួយដែល ពាក់ព័ន្ធទៅនឹងសំណង់ទៅកាន់ជនរងគ្រោះ ព្រមទាំងជួយកាត់បន្ថយនូវបញ្ហាដែលកើតមានឡើងនៅក្នុងសង្គមបានមួយចំណែកផងដែរ។ ដូចនេះក្រៅពីរាជរដ្ឋាភិបាល យើងគ្រប់រូបក៏មានតួនាទីសំខាន់នៅក្នុងបញ្ហាសំណង់នេះដែរ ព្រោះដើម្បីកុំឲ្យមានជនរងគ្រោះណាមួយដែលទទួលរងនូវការខូចខាតដោយសារតែបញ្ហាសំណង់នេះ និងដើម្បីកុំឲ្យបុគ្គលណាម្នាក់ក្លាយជាជនបង្កឲ្យកើត មាននូវព្យសនកម្មតទៅទៀត។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ប្រកាសឲ្យប្រើនៅថ្ងៃទី ០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ ប្រកាសឲ្យប្រើនៅថ្ងៃទី ០៦ កក្កដា ២០០៦
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២ ប្រកាសឲ្យប្រើនៅថ្ងៃទី ៣០ វិច្ឆិកា ២០០៩
- ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥ ប្រកាសឲ្យប្រើនៅថ្ងៃទី ១៦ កក្កដា ២០១៤
- ច្បាប់ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩ ប្រកាសឲ្យប្រើនៅថ្ងៃទី ១៨ តុលា ២០១៩
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧ ប្រកាសឲ្យប្រើនៅថ្ងៃទី ៩ ឧសភា ២០១១
- ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា, លេខ ៥០៧/សហវ.ប្រក ប្រកាសឲ្យប្រើនៅថ្ងៃទី ២៦ មេសា ២០១៧
- ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ប្រកាសឲ្យប្រើនៅថ្ងៃទី២៨ តុលា ១៩៨៨
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, អនក្រ.បក ប្រកាសឲ្យប្រើនៅថ្ងៃទី ៣០ ធ្នូ ២០២០

## ឯកសារផ្សេងៗ

- សេចក្តីពន្យល់ អំពីចំណុចសំខាន់ៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ នីតិវិធីចេញសាលក្រម (គន្ថី ១ ដល់ គន្ថីទី៥, គន្ថីទី៨ ដល់គន្ថីទី៩)
- អង្គការ អ៊ី-ដាប់ប៊ែលយូ-អ៊ែម-អាយ (East-West Management Institute.Inc. (EWMI) គ្មានកាលបរិច្ឆេទ , ច្បាប់អចលនវត្ថុកម្ពុជា: ទិដ្ឋភាពរួម
- ឯកឧត្តម ហ៊ី សោភា, គ្មានកាលបរិច្ឆេទ, មេរៀនស្តីពី អំពើអនីត្យានុកូល
- លោក គង់ សុភ័ក្ត្រ, អំពើអនីត្យានុកូល, ២០១៩-២០២០
- លោកស្រី ស្រី វណ្ណធី, នីតិរដ្ឋប្បវេណី, ២០១៦. បោះពុម្ពលើកទី២. រាជធានីភ្នំពេញ
- លោក អ៊ុំ ប៉ូលី, គ្មានកាលបរិច្ឆេទ, អំពើអនីត្យានុកូល
- លោក សួស ចំរើន, គ្រប់គ្រងសំណង់, ២០០៣
- លោក កៅ សីហា, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ២០១០
- លោក ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ២០១០
- សន្ទានុក្រមនៃច្បាប់ស្តីពីសំណង់ ,២០១៩
- លោក ខាំ សុមករា, គ្មានកាលបរិច្ឆេទ, អំពើអនីត្យានុកូល

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាម៉ៅការតំសំណង់</u>

កិច្ចសន្យានេះ ធ្វើនៅរាជធានីភ្នំពេញ ចុះថ្ងៃទី.............ខែ ………… ឆ្នាំ **២០...** ដោយរវាងៈ

លោកស្រី ……………………ភេទ …………..កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ…………………......មានទីតាំងស្ថិតនៅ ផ្ទះ ……. ផ្លូវ ……. សង្កាត់ ………… ខណ្ឌ ………… រាជធានីភ្នំពេញកាន់ទូរសព្ទ័លេខ ……………………… ដែលជា **ភាគីអ្នកតំណាងម្ចាស់សំណង់អាគារ** ចាប់ពីពេលនេះទៅហៅកាត់ថា **ភាគី"ក"** ។

**និង**

លោក .......... ភូមិ........... ឃុំ ........ ស្រុក .........ខេត្ត....... កាន់ទូរសព្ទ័ លេខ ......... ដែលជា**ភាគីអ្នកម៉ៅការ** ចាប់ពីពេលនេះទៅហៅកាត់ថា**ភាគី "ខ"** ។

**ក្រោយពីបានពិភាក្សាគ្នា ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ**

**ប្រការ ១ ៖ កម្មវត្ថុនៃកិច្ចសន្យា**

**ភាគី"ក"** បានព្រមព្រៀងឲ្យ **ភាគី"ខ"** ទទួល ម៉ៅការសំណង់ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ……….. ភូមិ …… ផ្លូវ ………សង្កាត់ ………… រាជធានីភ្នំពេញ ឲ្យចប់សព្វគ្រប់ទៅតាមប្លង់ និងគំរោងបញ្ជីប៉ាន់ស្មានតម្លៃភ្ជាប់មកជាមួយ ដែលមានតម្លៃសរុប **$** ………………………… ( ………………………………………………… )

**ប្រការ ២៖ រយៈពេលនៃការសាងសង់**

កិច្ចសន្យាសាងសង់អគារនេះមានរយៈពេល………ខែ ដោយគិតចាប់ពី ថ្ងៃទី…… ខែ …….. ឆ្នាំ ……… រហូតដល់ ថ្ងៃទី ……… ខែ ……… ឆ្នាំ ………… ។

**ប្រការ ៣ ៖ តំណាក់កាលនៃការទូទាត់ប្រាក់**

៣-១ ភាគី"ក" បានព្រមព្រៀងឲ្យ ភាគី"ខ" ទទួលម៉ៅការសាងសង់អគារនេះដូចមានចែងក្នុងប្រការ១ខាងលើនេះ តាមតម្លៃព្រមព្រៀងដូចមានកំណត់ក្នុងតារាងទូទាត់ប្រាក់ដែលភាគីទាំងពីរបានផ្តិតមេដៃស្តាំទទួលស្គាល់ និងឯកភាពគ្នាជាឧបសម្ព័ន្ធភ្ជាប់(តារាងទូទាត់ប្រាក់) ជាមួយកិច្ចសន្យានេះ។

៣-២ ភាគី"ក" ត្រូវធ្វើការទូទាត់ប្រាក់ដែលមានចែងកំណត់ក្នុងតារាងទូទាត់ប្រាក់សំរាប់ការងាររយៈពេល ទៅឲ្យ ភាគី"ខ"។ ភាគី"ខ" នឹងដាក់សំណើរសុំទូទាត់ប្រាក់ជូន ភាគី"ក" ចំនួន

៣ថ្ងៃមុនការទូទាត់ប្រាក់ម្តងៗ ក្នុងករណីបើ ភាគី” ក” មានការយឺតយ៉ាវក្នុងការទូទាត់ប្រាក់តាមកាលកំណត់ នោះ ភាគី” ក” ត្រូវទទួលការផាកពិន័យលើការយឺតយ៉ាវក្នុង១ថ្ងៃស្មើនឹង 0.1%នៃតម្លៃគម្រោងសរុបសនៃផាក់ពិន័យនេះសំរាប់7ថ្ងៃ បន្ទាប់ដោយគិតចាប់ពីថ្ងៃទូទាត់និមួយៗ ក្នុងករណីបើការខកខានមិនបានបង់ប្រាក់ តាមកាលកំណត់នេះចាប់ពីរយៈពេលមួយខែដោយគិតចាប់ពីថ្ងៃទូទាត់និមួយៗ នោះភាគី ” ខ” មានសិទ្ធិរំលាយកិច្ចសន្យាសាងសង់ជាឯកតោភាគី ហើយ ភាគី” ក” ត្រូវទទួលខុសត្រូវសងសំណងការខូចខាតជាក់ស្តែង រួមបញ្ចូលទាំងប្រាក់ពិន័យជូន ភាគី” ខ” ដោយគ្មានលក្ខខណ្ឌ។

ផ្ទុយទៅវិញក្នុងករណីភាគី” ខ” មានការយឺតយ៉ាវក្នុងការសាងសង់តាមពេលវេលាដែលបានកំណត់ នោះ ភាគី” ខ” ត្រូវទទួលការផាកពិន័យលើការយឺតយ៉ាវក្នុង ១ថ្ងៃ ស្មើនឹង0.1%នៃតម្លៃគម្រោងសរុប នៃផាក់ពិន័យនេះសំរាប់ ២សប្តាហ៍ បន្ទាប់ ដោយគិតចាប់ពីថ្ងៃកំណត់បញ្ចប់ការសាងសង់ ដែលបានកំណត់ពេលវេលាសាងសង់។

<u>បញ្ជាក់</u> រាល់ខ្លឹមសារនៃពេលវេលាកំណត់ខាងលើនេះ ក្នុងករណី ភាគី” ក” មិនមានការកែតម្រូវលើប្លង់ ក៏ដូចជាការងារបន្ថែម។

**ប្រការ ៥៖ សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី“ក”**

**ភាគី“ក” មានភាតព្វកិច្ចដូចតទៅ ៖**

៥-១ **ភាគី“ក”** ជាអ្នកទទួលខុសត្រូវដោះស្រាយក្នុងករណីដែលដំណើរការសាងសង់ត្រូវបានអាជ្ញាធរហាមឃាត់ឲ្យបានរួចរាល់ទាំងស្រុង។ ចំពោះរយៈពេលនៃកិច្ចសន្យាសាងសង់ដែលមានចែងក្នុងប្រការ២ ត្រូវពន្យាទៅតាមរយៈពេលដែល **ភាគី“ក”** ដោះស្រាយជាមួយអជ្ញាធរដោយ **ភាគី“ក”** មិនអាចលើកយកបញ្ហានេះ(ការយឺតយ៉ាវ) មកធ្វើជាមូលហេតុដើម្បីបញ្ចប់កិច្ចសន្យានេះបានឡើយ។

៥-២ **ភាគី“ក”** យល់ព្រមទទួលខុសត្រូវលើការទូទាត់ប្រាក់គ្រប់ចំនួនពេញថ្លៃឲ្យ **ភាគី“ខ”** និងទាន់ពេលវេលា ដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើនេះ តាមតម្លៃព្រមព្រៀងដូចមានកំណត់ក្នុងតារាងទូទាត់ប្រាក់ដែលភាគីទាំងពីរបានផ្តិតមេដៃស្តាំទទួលស្គាល់ និងឯកភាពគ្នាជាឧបសម្ព័ន្ធភ្ជាប់ជាមួយកិច្ចសន្យានេះ។

៥-៣ **ភាគី“ក”** យល់ព្រមលើការស្នើរសុំពី**ភាគី“ខ”** លើការទូទាត់ប្រាក់ចំនួន 35%ដំបូងនៅពេលចុះកិច្ចសន្យា ដែលមានតម្លៃ **$**............... ទៅឲ្យ**ភាគី “ខ”**ដូចមានកំណត់ក្នុងតារាងទូទាត់ប្រាក់ដែលភាគីទាំងពីរបានផ្តិតមេដៃស្តាំទទួលស្គាល់ និងឯកភាពគ្នាជាឧបសម្ព័ន្ធភ្ជាប់ជាមួយកិច្ចសន្យានេះ។

៥-៤ **ភាគី"ក"** ជាអ្នកទទួលរ៉ាប់រងផ្តល់ទឹក ភ្លើង100% នៃការប្រើប្រាស់ និងកន្លែងដាក់សម្ភារៈឲ្យ **ភាគី"ខ"** ក្នុងការអនុវត្តការងារ។

៥-៥ **ភាគី"ក"** ត្រូវជូនដំណឹង **ភាគី"ខ"** ឲ្យបានទាន់ពេលវេលាចំពោះបរិមាណការងារដែលលើស ឬខ្វះក្នុងករណីផ្លាស់ប្តូរប្លង់ថ្មី ជៀសវាងការផ្លាស់ប្តូរប្លង់ថ្មីនាំឲ្យប៉ះពាល់ដល់ដំណើរការសាងសង់ដែលបានធ្វើរួចហើយត្រូវផ្លាស់ប្តូរតាមប្លង់ថ្មី។

៥-៦ នៅក្នុងរយៈពេលនៃការអនុវត្តកិច្ចសន្យានេះ **ភាគី"ក"** មិនត្រូវរំខានដល់ការសាងសង់របស់ **ភាគី"ខ"** ឡើយប្រសិនបើ **ភាគី"ខ"** បានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា តាមផ្លូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៥ ៖ សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី"ខ"

**ភាគី"ខ" មានកាតព្វកិច្ចដូចតទៅ ៖**

៦-១ **ភាគី"ខ"** មិនអាចផ្ទេរសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យាជួលនេះទៅឲ្យតតិយជនណាមួយដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពី **ភាគី"ក"** បានឡើយ ក្នុងករណី **ភាគី"ក"** មិនយល់ព្រមតាមសំណើររបស់ **ភាគី"ខ"** **ភាគី"ក"** ត្រូវមានមូលហេតុសមរម្យ។

៦-២ **ភាគី"ខ"** ត្រូវធានាលើគុណភាពតំឡើងប្រពន្ធ័ទឹក-ភ្លើងទៅតាមលក្ខណៈបទដ្ឋានបច្ចេកទេស និងគំនូរប្លង់ ឲ្យបានត្រឹមត្រូវ និងតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ព្រមទាំងធ្វើឲ្យបានសម្រេចតាមកាលកំណត់ដូចមានចែងក្នុងប្រការ២ នៃកិច្ចសន្យា។

៦-៣ **ភាគី"ខ"** មិនធានាចំពោះការខូចខាតដោយប្រធានសក្តិ គ្រោះធម្មជាតិ កត្តានយោបាយសង្គម ឬការខូចខាតដែលបណ្តាលមកពី **ភាគី"ក"** ខ្លួនឯង ។

**ភាគី"ខ"** ត្រូវ ធានាចំពោះអគ្គីភ័យ ដែលបង្ករលើដោយក្រុមការងាររបស់ខ្លួន។

៦-៤ **ភាគី"ខ"** ជាអ្នកទទួលខុសត្រូវក្នុងការធានាសុខសុវត្ថិភាពបុគ្គលិកកម្មករដែលបំរើការនៅក្នុងការដ្ឋានរបស់ខ្លួន។

៦-៦ **ភាគី"ខ"** ធានាលើសេវាប្រើប្រាស់រយៈពេល.......ឆ្នាំ ក្នុងការជួសជុលនិងបញ្ហាផ្សេងៗ ដែលកើតមានលើការងារសាងសង់ ។

៦-៧ **ភាគី"ខ"** **ទទួលខុសត្រូវ**រាល់ការងារដែលពាក់ព័ន្ធនិងសំណង់អគារ ដែរត្រូវបានក្រុមការងារ**ភាគី"ខ"** ជាអ្នកធ្វើអោយខូចទ្រង់ទ្រាយដើមក្នុងការបំពេញការងារអោយត្រូវទៅតាមបទដ្ឋាន ត្រូវទទួលបន្ទុកក្នុងការធ្វើឡើងវិញ អោយបានស្អាតទៅតាមគំរូដើម ។

៦-៨ **ភាគី"ខ"** ទទួលខុសក្នុងការសម្អាតការដ្ឋានដែលជាការងាររបស់ខ្លួនអោយបានត្រឹមត្រូវក្រោយបញ្ចប់ការងាររួចរាល់ ។

## ប្រការ ៦ ៖ ការកែប្រែ និងការបញ្ចប់កិច្ចសន្យា

៧-១ កិច្ចសន្យានេះ អាចកែប្រែបានដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីគូរភាគីទាំងសងខាង។

៧-២ ក្នុងការអនុវត្តការងារប្រសិនបើ **ភាគី"ក"** ពិនិត្យឃើញថា ការសាងសង់ ពុំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ឬពុំត្រឹមត្រូវតាមកិច្ចសន្យាដូចមានចែងក្នុងប្រការ៦ នោះ**ភាគី"ក"** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យ **ភាគី"ខ"** កែតម្រូវ។ ករណី **ភាគី"ខ"** មិនកែតម្រូវតាមក្នុងរយៈពេល១៥ថ្ងៃ នោះ **ភាគី"ក"** មានសិទ្ធិបញ្ចប់កិច្ចសន្យានេះ។

## ប្រការ ៧ ៖ ការអនុវត្តកិច្ចសន្យា

៨-១ កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀងពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំហើយរាល់ការកែប្រែ ឬធ្វើវិសោធនកម្មលើផ្នែកណាមួយ ឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីគូភាគីទាំងសងខាងដូចមានចែងក្នុងប្រការ៧-១ ខាងលើ។

៨-២ គូភាគីទាំងពីរនៃកិច្ចសន្យាត្រូវសហការគ្នាអនុវត្តកិច្ចសន្យានេះ អោយបានល្អត្រឹមត្រូវប្រកបដោយបរិយាកាសទុកចិត្តគ្នា និងស្មោះត្រង់ទៅវិញទៅមក។ ភាគីនិមួយៗមិនត្រូវបង្កការរាំងស្ទះ ឬបង្កឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតឡើយ។ ភាគីទាំងអស់នៃកិច្ចសន្យាត្រូវតែអនុវត្តឲ្យបានទៀងទាត់ និងពេញលេញ នូវរាល់កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យានេះ។

ករណីដែលភាគីណាមួយខកខានមិនបានអនុវត្តឬអនុវត្តមិនបានពេញលេញតាមកាតព្វកិច្ចទាំងឡាយនៃកិច្ចសន្យា នោះភាគីម្ខាងទៀតអាច ៖

- តម្រូវឲ្យភាគីម្ខាងទៀតអនុវត្តឲ្យបានត្រឹមត្រូវឡើងវិញ
- រំលាយកិច្ចសន្យាដោយឯកតោភាគី។

ភាគីដែលមានកំហុសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងត្រូវសងសំណងខូចខាតនានាដែលកើតឡើងចំពោះភាគីម្ខាងទៀត។

## ប្រការ ៨ ៖ អានុភាពនៃកិច្ចសន្យា

កិច្ចសន្យានេះមានអានុភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងតែចំពោះភាគីប៉ុណ្ណោះ។ ក្នុងករណីដែលភាគីណាមួយនៃកិច្ចសន្យាមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ដោយ

មូលហេតុអសមត្ថភាព មរណភាព នោះសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលមរតកបន្តពីភាគី នោះ ត្រូវអនុវត្តកាតព្វកិច្ចទាំងឡាយនៃកិច្ចសន្យានេះឲ្យបានចប់ចុងចប់ដើម។

**ប្រការ ៩ ៖ ករណីប្រធានសក្តិ**

កាតព្វកិច្ចទាំងឡាយរបស់ភាគីនៅក្នុងកិច្ចសន្យានេះ ត្រូវរលត់នៅពេលមានករណីប្រធានសក្តិកើតមានឡើងដែលមិនអាចឲ្យភាគីអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។ ករណីប្រធានសក្តិដែលអាចយកជាការបានរួមមាន ៖ សង្គ្រាម ទឹកជំនន់ធ្ងន់ធ្ងរ ចលាចលទូទាំងប្រទេស ដែលបណ្តាលឲ្យការអនុវត្តកាតព្វកិច្ចមិនអាចប្រព្រឹត្តទៅបាន។

**ប្រការ ១០ ៖ ច្បាប់គ្រប់គ្រង និងតុលាការមានសមត្ថភាព**

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងលើកិច្ចសន្យានេះ គឺច្បាប់ និងលិខិតបទដ្ឋាន។
- គតិយុត្តជាធរមានទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា។
- តុលាការដែលមានសមត្ថកិច្ចដោះស្រាយវិវាទលើកិច្ចសន្យានេះ គឺតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១១ ៖ ការដោះស្រាយវិវាទ**

ក្នុងករណីមានវិវាទដែលបណ្តាលមកពីការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យានេះ ភាគីទាំងពីរបានឯកភាពគ្នាដោះស្រាយតាមដំណាក់កាលដូចខាងក្រោម ៖

- ចរចារ សម្រុះសម្រួលឲ្យអស់លទ្ធភាពជាមុន
- ក្នុងរយៈពេល ០៧(ប្រាំពីរ)ថ្ងៃ បើការចរចានៅតែគ្មានលទ្ធផល នោះភាគីណាមួយអាចប្តឹងទៅតុលាការស្របតាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១២ ៖ ប្រសិទ្ធិភាពអនុវត្តន៍**

កិច្ចសន្យានេះមានប្រសិទ្ធិភាពអនុវត្តទាំងស្រុងសំរាប់គូភាគី ហើយចំពោះកិច្ចសន្យាមៅការសាងសង់ ឬកិច្ចព្រមព្រៀងណាមានខ្លឹមសារផ្ទុយនឹងកិច្ចសន្យានេះត្រូវចាត់ទុកជា និរាករណ៍។

កិច្ចសន្យានេះ ធ្វើឡើងជាភាសារខ្មែរចំនួន 02(ពីរ)ច្បាប់ដែលក្នុងនោះ ៖

- ០១ (មួយ)ច្បាប់ តម្កល់ទុកនៅ **ភាគី"ក"**
- ០១ (មួយ)ច្បាប់ តម្កល់ទុកនៅ **ភាគី"ខ**

កិច្ចសន្យានេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះកិច្ចសន្យានេះតទៅ។

ភាគីទាំងពីរនៃកិច្ចសន្យានេះ បានអាន និងយល់រាល់ខ្លឹមសារទាំងឡាយដែលមានចែង ក្នុងកិច្ចសន្យានេះ ហើយយល់ព្រមផ្តិតមេដៃស្តាំ ដើម្បីទុកជាសក្ខីភាពចំពោះមុខច្បាប់។

**ស្នាមមេដៃស្តាំនិងហត្ថលេខាគូភាគី**

**ភាគី"ក"** **សាក្សី ភាគី"ក"** **ភាគី"ខ"** **សាក្សីភាគី"ខ"**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

## ពាក្យសុំលិខិតអនុញ្ញាតសាងសង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ...........................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទី...........សង្កាត់................................ ខណ្ឌ........................................រាជធានីភ្នំពេញ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ...........................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទី...........សង្កាត់................................ ខណ្ឌ........................................រាជធានីភ្នំពេញ។

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ** : - ចៅសង្កាត់.......................................................................................
- អភិបាលខណ្ឌ.....................................................................................
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំ.............................................................. លើដីឡូត៍លេខ.......................ផ្លូវលេខ................ ភូមិ.....................សង្កាត់.........................................ខណ្ឌ..............................................រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា:

......................................................................................................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមឯកឧត្តម មេត្តាអនុញ្ញាតច្បាប់អោយដល់ខ្ញុំបាទ-នាងខ្ញុំ កាន់កាប់ .................................................................................................. ដោយអនុគ្រោះ ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ-នាងខ្ញុំ។

**<u>សូមជូនភ្ជាប់មកជាមួយនូវ :</u>**

- ច្បាប់ថតចំលងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន.................ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន.................ច្បាប់
- សលាកប័ត្រដីឡូត៍ ចំនួន.................ច្បាប់
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចំនួន.................ច្បាប់
- កិច្ចសន្យាសាងសង់ ចំនួន.................ច្បាប់
- ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណ ចំនួន.................ច្បាប់

ភ្នំពេញ,ថ្ងៃទី.........ខែ.............ឆ្នាំ២០.....
**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

លេខ:....................
បានឃើញ និង បញ្ជូនមក
លោកអភិបាលខណ្ឌ.............................
-ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ-
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**ចៅសង្កាត់**.........................

លេខ:....................
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។
-ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ-
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**អភិបាលខណ្ឌ**.........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ២៤១៧ ដនស/អរប.

ថ្ងៃពុធ ៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០១៨

**ជម្រាបជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ**

**កម្មវត្ថុ** : ការបញ្ឈប់ផ្តល់គោលការណ៍ឱ្យដំណើរការសាងសង់ មុនទទួលបានលិខិតអនុញ្ញាតសាងសង់ពីស្ថាប័នមានសមត្ថកិច្ច

**យោង** :
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- លិខិតលេខ ៤០៧/១៨ សជណ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ
- ស្មារតីកិច្ចប្រជុំនាថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៨

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត** ជ្រាបថា ការដ្ឋានសំណង់ជាច្រើនក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ បាននិងកំពុងដំណើរការសាងសង់ ខ្លះជិតរួចរាល់ទាំងស្រុងទៅហើយ ដោយពុំមានលិខិតអនុញ្ញាតសាងសង់ មានតែគោលការណ៍ឱ្យដំណើរការសាងសង់មុនទទួលបានលិខិតអនុញ្ញាតសាងសង់ ចេញដោយរដ្ឋបាលខេត្តព្រះសីហនុ ផ្ទុយទៅនឹងស្មារតីនៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ បណ្តាលឱ្យកើតមានបទល្មើសសំណង់ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភណ្ឌភាព និងគុណភាពសំណង់។

ក្នុងន័យនេះ ក្រសួងស្នើរដ្ឋបាលខេត្តព្រះសីហនុបញ្ឈប់ការចេញលិខិតអនុញ្ញាតជាគោលការណ៍ដល់ម្ចាស់សំណង់ឱ្យដំណើរការសាងសង់មុនទទួលបានលិខិតអនុញ្ញាតសាងសង់ពីស្ថាប័នមានសមត្ថកិច្ច និងត្រូវពង្រឹងការគ្រប់គ្រងការដ្ឋានសំណង់ឱ្យគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបច្ចេកទេសជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិបាលខេត្ត** ជ្រាប និងចាត់ចែងអនុវត្ត។

សូម **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត** ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជា សុផារ៉ា**

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**ឆាន់ សាផាន**

អាសយដ្ឋាន: ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ /ទូរសារ (885) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាសាងសង់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................................................ភេទ..........អាយុ..........ឆ្នាំ សញ្ជាតិ.................
ដែលមានទីលំនៅបច្ចុប្បន្នផ្ទះលេខ..................ផ្លូវលេខ..............ក្រុមទី............ភូមិ.......... សង្កាត់.........................
ខណ្ឌ...................................រាជធានីភ្នំពេញ។

ប្តី-ប្រពន្ធ ឈ្មោះ..........................................................ភេទ..........អាយុ..........ឆ្នាំ សញ្ជាតិ.................
ដែលមានទីលំនៅបច្ចុប្បន្នផ្ទះលេខ..................ផ្លូវលេខ..............ក្រុមទី............ភូមិ.......... សង្កាត់.........................
ខណ្ឌ...................................រាជធានីភ្នំពេញ។

### <u>សូមធ្វើកិច្ចសន្យា ដូចតទៅ</u>

១-គោរពតាមខ្លឹមសារអនុក្រឹត្យ លេខ ៨៦ អនក្រ បានកំណត់។
២-ធានាសុវត្ថិភាពរបស់អ្នកជិតខាង ដែលមានទីតាំងសាងសង់ សំណង់មុន។
៣-ធានាមិនឱ្យកាកសំណល់ ទឹកកង្វក់ចូលទៅប៉ះពាល់ទីកន្លែងបរិស្ថានរបស់ប្រជាជនជុំវិញ ឬទីសាធារណៈ ឡើយ។
៤-ធានាការពារមិនឱ្យមានអគ្គីភ័យកើតមានឡើង ក្នុងករណីកើតមានជាយថាហេតុណាមួយនេះ ខ្ញុំបាទ-នាងខ្ញុំ យល់ព្រមចេញសងនូវការខូចខាតទាំងឡាយរបស់អ្នកដទៃនៅជិតខាងនោះ។
៥-ក្នុងករណីទៅថ្ងៃក្រោយ បើមានការប៉ះពាល់សោភ័ណ្ឌភាព សណ្តាប់ធ្នាប់សាធារណៈបរិស្ថាន ឬការពង្រីកផ្លូវ នៅពេលអនាគត ខ្ញុំបាទ-នាងខ្ញុំ សុខចិត្តគោរពតាមគោលការណ៍កំណត់ របស់សមត្ថកិច្ចរដ្ឋ។

ខ្ញុំបាទ-នាងខ្ញុំសូមសន្យាថា នឹងគោរពតាមកិច្ចសន្យានេះទាំងស្រុង ហើយសូមទទួលខុសត្រូវចំពោះមុខច្បាប់ របស់រដ្ឋជាធរមាន ក្នុងករណីប្រព្រឹត្តខុសពីកិច្ចសន្យាខាងលើ។

ភ្នំពេញ,ថ្ងៃទី.........ខែ............ឆ្នាំ២០.....
**ស្នាមមេដៃស្តាំ**

លេខៈ........................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃស្តាំរបស់ឈ្មោះ
.................................................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី.........ខែ..............ឆ្នាំ២០......
**ចៅសង្កាត់**..........................

លេខៈ........................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងស្តាំនេះ ពិតជាស្នាមមេដៃស្តាំរបស់លោក
........................ចៅសង្កាត់......................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី.........ខែ..............ឆ្នាំ២០......
**អភិបាលខណ្ឌ**................................

ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំពឹងពាក់មេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................អាយុ...........ឆ្នាំ សញ្ជាតិ....................
មុខរបរ.................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ផ្លូវ...........ក្រុម...........
ភូមិ.........................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ..............................
ខេត្ត/រាជធានី.....................ត្រូវជា.........................................។

## សុំពឹងពាក់

លោក/លោកស្រីមេធាវី.....................អត្តលេខ..........ការិយាល័យ..........................
................................................អាសយដ្ឋានផ្ទះលេខ..................................................
ផ្លូវលេខ..........ភូមិ.....................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ.....................
ខេត្ត/រាជធានី....................ដើម្បីការពារសិទ្ធិអោយខ្ញុំបាទ/នាងខ្ញុំនៅចំពោះមុខ.......................
.......................................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ...........ចុះថ្ងៃទី.......ខែ.........ឆ្នាំ...
........របស់.........................................................ក្នុងនាមជា: ...................................។

ខ្ញុំសូមអះអាងថា រឿងក្តីនេះមិនមានទំនាក់ទំនងពឹងពាក់មេធាវីតំណាង ឬការពារណាមួយទេ។

ចាប់ពីថ្ងៃខ្ញុំបាទ/នាងខ្ញុំចុះហត្ថលេខា រឺផ្តិតម្រាមដៃនេះតទៅ គឺមេធាវីខាងលើមានសិទ្ធិការពារផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ.......................ថ្ងៃទី...........ខែ............ឆ្នាំ..........

**ស្នាមម្រាមដៃសាមីខ្លួន**

បានឃើញ និង យល់ព្រម

ធ្វើនៅ.................ថ្ងៃទី........ខែ............ឆ្នាំ.............

**ហត្ថលេខា និង ត្រា**

**ពាក្យបណ្តឹងគំរូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

- ដើមចោទ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ ......... រាជធានីភ្នំពេញ/ខេត្ត............

- ចុងចម្លើយ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ ......... រាជធានីភ្នំពេញ/ខេត្ត............

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ/ខេត្ត**..............

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ............
២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ...................
៣. ...............
៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ៖**

.....................................................................................................................
.....................................................................................................................
.....................................................................................................................។

**គ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖**

.....................................................................................................................
.....................................................................................................................
.....................................................................................................................។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមពាក្យបណ្តឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ................ កើត/រោច ខែ............ ឆ្នាំ....... ............ស័ក ព.ស. ២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.................. ឆ្នាំ២០..........

**ស្នាមមេដៃស្តាំ**

**ឯកសារថតចម្លងភ្ជាប់ជាមួយ៖**

១..................
២.................

គំរូលេខ០១សហវ/ចមព

00248859

1274156626930867

**ក្រសួងយុត្តិធម៌**

**អង្គភាព**..............................................

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី................................ អង្គភាព..............................................

ចំនួនទឹកប្រាក់ជាលេខ..............................................

ជាអក្សរ..............................................

អត្ថន័យចំណូល.............................. មាតិកាថវិកា..........

.........., ថ្ងៃទី ......ខែ ......ឆ្នាំ២០១...

អ្នកប្រមូលចំណូល

MINISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

១៤. **សៀវភៅបន្ទុក** សំដៅដល់កម្រងឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការអនុវត្តការងារសាងសង់ ឬរុះរើ មានជាអាទិ៍ផែនការការងារ សេចក្តីណែនាំបច្ចេកទេស វិធីសាស្ត្រ និងឯកសារបច្ចេកទេសដទៃទៀត។

១៥. **សំណង់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ** សំដៅដល់សំណង់ជាកេរដំណែលបន្សល់ទុកពីមនុស្សជំនាន់មុនដែលមានចរិតវិទ្យាសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ បុរាណវិទ្យា សិល្បៈ សាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ និងដែលបានចុះបញ្ជីសារពើភណ្ឌ បេតិកភណ្ឌស្របតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។

១៦. **សំណង់មិនមែនអគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីឬអចលនវត្ថុដទៃទៀតសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងមិនមែនសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍បង្គោលអង់តែនទូរសព្ទ បង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍ សំណង់ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ទ្រីម បង្គោលអគ្គិសនី ជញ្ជាំងទប់ ប៉ម ខ្លោងទ្វារ អាងស្តុកទឹកខ្ពស់ពីដី ស្តូប បដិមា កន្ត្រកវិល។

១៧. **សំណង់លំនៅឋាន** សំដៅដល់សំណង់ដែលមានមុខងារប្រើប្រាស់ជាទីលំនៅអចិន្ត្រៃយ៍។

១៨. **អគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍សំណង់លំនៅឋាន សណ្ឋាគារ អគារការិយាល័យ មន្ទីរពេទ្យ អគារសិក្សា បណ្ណាល័យ រោងភាពយន្ត សារមន្ទីរ សាលមហោស្រព ផ្សារ រោងចក្រ ស្ថានីយអ្នកដំណើរ។

១៩. **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២០. **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់រុះរើ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក លិខិតបញ្ជាក់អនុលោមភាព វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត។

## ជំពូកទី២

## សមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មី សរុបលើសពី៣ ០០០ (បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង៥(ប្រាំ)ម៉ែត្រ
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ថបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយឬដេប៉ូស្តុក លក់ ឬចែកចាយប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលគេលសិលាដទៃទៀត ពោងឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឧស្ម័ន សារធាតុងាយឆេះ ឬផលិតផលគេលសិលាដទៃទៀត និងរោងជាងដែលមានផលិតផលងាយឆេះ
- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី៥០(ហាសិប) ម៉ែត្រគុប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអយស្ម័យយាន កំពង់ផែ អាកាសយានដ្ឋាន និងស្ថានីយវារីអគ្គិសនី ដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរសព្ទនិងបង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង៣០(សាមសិប)ម៉ែត្រ។

**មាត្រា៥ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតុះរើ ចំពោះសំណង់ឬការងារ ដូចខាងក្រោមៈ

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា និង មានកម្ពស់ទាបជាងឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មានឬមានជាន់ក្រោមដីក្នុង

ជម្រៅរាក់ជាងឬស្មើ៥(ប្រាំ)ម៉ែត្រ លើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី៥០០(ប្រាំរយ)ម៉ែត្រក្រឡា និងតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្មឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ទាបជាងឬស្មើ៣០(សាមសិប)ម៉ែត្រ។

**មាត្រា៦ .-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារដូចខាងក្រោម៖

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្មឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី)ម៉ែត្រ។

**មាត្រា៧ .-**

រាជរដ្ឋាភិបាលឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យសាងសង់ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពរូបិយបណ្ណ តម្កល់ និងរក្សាទុករូបិយវត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិនិងការការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធនិងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

# ជំពូកទី៣

## គោលការណ៍ទូទៅនៃការផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**មាត្រា៨ .-**

រាល់ការសាងសង់ឬរុះរើ ត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច លើកលែងតែការងារមួយចំនួនដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច ចំពោះការស្នើសុំលិខិតអនុញ្ញាត ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច បានផ្ដល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។

សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីលិខិតអនុញ្ញាតដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដី និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីជាធរមាន។

**មាត្រា៩ .-**

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្ដល់លិខិតអនុញ្ញាត អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចនោះ ត្រូវចេញលិខិតជូនដំណឹងនិងតម្រូវឱ្យម្ចាស់សំណើមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនវិញ។

ក្នុងករណីម្ចាស់សំណើមិនមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចអាចសម្រេចមិនរក្សាទុកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតនោះបាន។

**មាត្រា១០ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវយកទៅដាក់នៅ៖

១. ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់លិខិតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់លិខិតផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត អាចផ្តល់ជូនម្ចាស់សំណើ តែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណី សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយ ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំឡើយ។

**មាត្រា១១ .-**

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១២ .-**

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំនោះ

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះលិខិតអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះលិខិតអនុញ្ញាតផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះលិខិតអនុញ្ញាតផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្ដីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដែលគម្រោងប្លង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

## ជំពូកទី៤
## លិខិតអនុញ្ញាតសាងសង់

**មាត្រា១៣ .-**

មានតែកម្មសិទ្ធិករនៃដីនិងអ្នកដែលបានកាន់កាប់ដីស្របច្បាប់ ទើបអាចអនុញ្ញាតឱ្យសាងសង់សំណង់នៅលើដីនោះបាន។

ការងារសាងសង់ មិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់បានឡើយ។

**មាត្រា១៤ .-**

ការងារសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិត ឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីការងារសាងសង់នោះអនុវត្តនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

**មាត្រា១៥ .-**

សំណង់ដែលការងារសាងសង់មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ មានដូចខាងក្រោម៖

- សំណង់អគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើដោយមានកម្រាលខណ្ឌធ្វើពីឈើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១០០(មួយរយ)

ម៉ែត្រក្រឡា មានកម្ពស់ទាបជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ និងមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ

- សំណង់មិនមែនបេតុងដែលសាងសង់ផ្ទាល់ដីសម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្ន មានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់នៅក្នុងបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ២០(ម្ភៃ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រ
- របងដែលមិនធ្វើអំពីថ្មឬបេតុង។

**មាត្រា១៦ .-**

ការងារកែប្រែដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទ្រង់ គ្រឿងផ្គុំសំណង់ និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ មានជាអាទិ៍៖

- ការប្តូរពណ៌ផ្នែកខាងក្នុង
- ការប្តូរទ្រង់ទ្រាយផ្នែកខាងក្នុងនៃសំណង់ ដូចជាបង្កាន់ដៃសុវត្ថិភាព ពិតានដែលមិនធ្វើពីបេតុងដែក ជញ្ជាំងខណ្ឌបន្ទប់ដែលមិនទ្រទ្រង់
- ការប្តូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្គុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម។

**មាត្រា១៧ .-**

មុននឹងធ្វើការសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៨ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិឬសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្ម និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយ